gef

UNDP
Cambodia



# ស្តាប់អ្នកភូមិពីការប្រែប្រួលអាកាសធាតុ

## របាយការណ៍វាយតម្លៃភាពងាយរងគ្រោះ

ខែវិច្ឆិកា ឆ្នាំ ២០១០

# មាតិកា


| | | |
|---|---|---|
| **១.** | **សេចក្តីសង្ខេប** | **២** |
| | **អក្សរកាត់** | **៤** |
| **២.** | **សេចក្តីផ្តើម** | **៦** |
| **៣.** | **គោលបំណងនិងវិធីសាស្ត្រ** | **៨** |
| ៣.១ | និយមន័យ *VRA* | ៨ |
| ៣.២ | គោលបំណង *VRA* | ៨ |
| ៣.៣ | ឧបករណ៏ *VRA* | ១០ |
| **៤.** | **ការរកឃើញនៅក្នុងឃុំទឹកក្រហម ខេត្តព្រះវិហារ** | **១៣** |
| ៤.១ | សាវតា | ១៣ |
| ៤.២ | ការវិភាគនិន្នាការ និងប្រភេទហានិភ័យនៃការប្រែប្រួលអាកាសធាតុ | ១៣ |
| ៤.៣ | ហានិភ័យនៃការប្រែប្រួលអាកាសធាតុនៅក្នុងឃុំទឹកក្រហម | ១៤ |
| ៤.៤ | ពិន្ទុនៅក្នុង VRA | ២៣ |
| ៤.៥ | ការវិភាគទិន្នន័យដែលប្រមូលបាន | ២៥ |
| **៥.** | **ការរកឃើញនៅក្នុងឃុំបុសលាវ ខេត្តក្រចេះ** | **៣២** |
| ៥.១ | សាវតា | ៣២ |
| ៥.២ | ការវិភាគនិន្នាការនិងប្រភេទហានិភ័យនៃការប្រែប្រួលអាកាសធាតុ | ៣៣ |
| ៥.៣ | ហានិភ័យនៃការប្រែប្រួលអាកាសធាតុក្នុងឃុំបុសលាវ | ៣៤ |
| ៥.៤ | ពិន្ទុនៅក្នុង VRA | ៤២ |
| **៦.** | **បទពិសោធន៍ចម្បងៗដែលទទួលបាន** | **៥០** |

# ១. សេចក្តីសង្ខេប



*កសិករពិបាកយល់ពីទ្រឹស្តីនៃការប្រែប្រួលអាកាសធាតុ ប៉ុន្តែពួកគាត់មានបទពិសោធច្បាស់លាស់ជាមួយឥទ្ធិពលរបស់វា ។*

ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាមួយដែលមិនអាចមើលរំលងបានឡើយ ។ សូម្បីតែកសិករនៅក្នុងឃុំទឹកក្រហម ខេត្តព្រះវិហារ និងឃុំបុសលាវ ខេត្តក្រចេះ ក៏បានសម្គាល់ឃើញនូវការផ្លាស់ប្តូរនៃអាកាសធាតុ នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ នៅក្នុងឃុំទឹកក្រហម កសិករយល់ឃើញថាពួកគេងាយរងគ្រោះពីផលប៉ះពាល់បណ្តាលមកពីគ្រោះរាំងស្ងួត ចំណែកឯកសិករនៅក្នុងឃុំបុសលាវវិញគិតថា ពួកគេងាយរងគ្រោះពីឥទ្ធិពលនៃគ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ ។ នៅក្នុងឃុំទឹកក្រហម កសិករនៅគ្រប់ភូមិទាំងអស់បានកត់សម្គាល់ឃើញថា គ្រោះរាំងស្ងួតកើតឡើងញឹកញាប់និងមានរយៈពេលយូរជាងមុន ។ ដូចគ្នានេះដែរ នៅក្នុងភូមិបុសលាវ បើទោះបីជាតំបន់នេះត្រូវបានគេដឹងថាងាយរងគ្រោះពីទឹកជំនន់ក៏ដោយ ក៏កសិករនៅក្នុងភូមិទាំងអស់សម្គាល់ឃើញថា គ្រោះរាំងស្ងួតបានកើតឡើងញឹកញាប់ជាងមុន ។ ជាទូទៅគ្រោះទឹកជំនន់ ទំនងជាកើតឡើងថេរក្នុងរយៈពេល៣០ឆ្នាំចុងក្រោយនេះ ហើយលើសពីនេះ កសិករខ្លះថែមទាំងគិតថាចំនួននៃគ្រោះទឹកជំនន់បានថយចុះទៀតផង ។

កសិករនៅក្នុងឃុំទាំងពីរយល់ឃើញថា ការប្រែប្រួលអាកាសធាតុកំពុងប៉ះពាល់ដល់ជីវភាពពួកគេនៅលើវិស័យមួយចំនួនដូចជា : ទីមួយគឺគ្រោះរាំងស្ងួតនិងកម្តៅប៉ះពាល់ជាអវិជ្ជមានដល់សុខភាពសត្វ ។ សត្វងាប់ដោយសារកម្តៅនិងជម្ងឺ ហើយចំនួននេះទំនងជាមានការកើនឡើងនៅក្នុងអំឡុងពេលមានគ្រោះរាំងស្ងួត ។ ទីពីរ កសិករយល់ឃើញថាការប្រែប្រួលអាកាសធាតុជះឥទ្ធិពលអវិជ្ជមានដល់ទិន្នផលស្រូវ ។ ទឹករីងស្ងួតដោយសារកម្តៅខ្លាំងនិងព្រះរាំងស្ងួតបានប៉ះពាល់ដល់ការលូតលាស់ដំណាំស្រូវដែលជាលទ្ធផលនាំឱ្យទិន្នផលស្រូវធ្លាក់ចុះ ។ផលប៉ះពាល់ដូចគ្នានេះក៏បានជះឥទ្ធិពលទៅលើការដាំដំណាំផ្សេងទៀតដូចជាបន្លែនិងដំណាំផ្តល់ប្រាក់ចំណូលជាដើម ។ ទីបីគឺ គ្រោះរាំងស្ងួតបានធ្វើឱ្យប្រភពទឹកដែលតិចស្រាប់រីងស្ងួត ដែលកត្តានេះបានកំហិតនូវលទ្ធភាពស្រោចស្រពក្នុង

អំឡុងពេលរាំងស្ងួត ដូចជាការធ្វើកសិកម្មនៅក្នុងរដូវប្រាំង ។នៅក្នុងឃុំបុសលាវ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទំនងជាកើតឡើងដោយសារការចុះរាក់នៃបឹងនិងទំនប់ បណ្តាលមកពីឥទ្ធិពលនៃការបាត់បង់ព្រៃឈើ និងការហូរច្រោះដី ។ ទីបួន គឺការប្រែប្រួលអាកាសធាតុបានប៉ះពាល់ដល់សុខភាពមនុស្ស ។ កសិករបានសម្គាល់ឃើញថាមានការកើនឡើងនូវជម្ងឺមួយចំនួនដូចជារាគរូសនិងជម្ងឺដែលទាក់ទងពោះនិងក្រពះ មូលហេតុដោយសារគុណភាពទឹកកាន់តែកខ្វក់នៅរដូវប្រាំង ។ជាចុងក្រោយកសិករនៅឃុំបុសលាវសម្គាល់ឃើញថាខ្យល់ព្យុះបានបំផ្លាញទំនប់ ផ្ទះសម្បែង និងផ្លូវថ្នល់ ។ កសិករគិតថាសុខភាពសត្វ សុខភាពមនុស្ស ធនធានទឹកនិងទិន្នផលដំណាំ នឹងត្រូវរងផលប៉ះពាល់ខ្លាំងបំផុត ប្រសិនបើឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុកើនឡើង ។ ពួកគេក៏គិតផងដែរថាការកើនឡើងនៃការប្រែប្រួលអាកាសធាតុនឹងនាំឱ្យមានការកើនឡើងអសន្តិសុខស្បៀង និងថយចុះនូវប្រាក់ចំណូល ។

ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពមិនមែនអាក្រក់និងអវិជ្ជមានទាំងអស់នោះទេ ។ កសិករនៅក្នុងតំបន់ទាំងពីរយល់ឃើញថាការគាំទ្រស្ថាប័នពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលនិងរាជរដ្ឋាភិបាល គឺមានតួនាទីសំខាន់ក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគាត់ទៅនឹងការប្រែប្រួលអាកាសធាតុ ។ការគាំទ្រនេះមានភាពពាក់ព័ន្ធយ៉ាងខ្លាំងនៅក្នុងឃុំបុសលាវ ដោយសារតំបន់នេះមានវត្តមានអង្គការមិនមែនរដ្ឋាភិបាលច្រើនកំពុងធ្វើប្រតិបត្តការ ។ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់នូវជំនួយមនុស្សធម៌ នៅពេលមានគ្រោះទឹកជំនន់ដូចជា ផ្តល់មុង ម្ហូបអាហារ តង់ និងជម្រកភៀសខ្លួនជាដើម ។ ភ្នាក់ងារសុខភាពសត្វភូមិដែលជួយដល់ការគ្រប់គ្រងសត្វចិញ្ចឹមគឺមានសារៈសំខាន់ផងដែរ ។ វត្តមានបឹងបួរនិងទំនប់នៅក្នុងឃុំបុសលាវនិងទឹកក្រហម ក៏មានតួនាទីសំខាន់ក្នុងការកាត់បន្ថយឥទ្ធិពល នៃការប្រែប្រួលអាកាសធាតុ ។ កសិករខ្លះនៅក្នុងឃុំទឹកក្រហមយល់ឃើញថា ព្រៃឈើអភិរក្សបាននឹងកំពុងផ្តល់អាហារនិងអនុផលព្រៃឈើដែលពួកគេអាចលក់ដូរបាននៅក្នុងរដូវមានចំណូលតិចនិងទទួលទិន្នផលទាប ។

នៅពេលដែលសួរអំពីឧបសគ្គចម្បងក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ កសិករនៅក្នុងឃុំទឹកក្រហមបានលើកឡើងថា កង្វះខាតធនធានទឹកគឺជាឧបសគ្គដ៏ធំជាងគេ ហើយបន្ទាប់មកគឺកង្វះខាតថវិកា កង្វះខាតលទ្ធភាពទទួលបានបច្ចេកទេសកសិកម្ម កង្វះខាតព័ត៌មានពីការប្រែប្រួលអាកាសធាតុនិងកង្វះខាតការគាំទ្រស្ថាប័ន ។នៅក្នុងឃុំបុសលាវ ឧបសគ្គធំៗរួមមានកង្វះខាតលទ្ធភាពទទួលបានពូជស្រូវដែលបានកែលម្អ កង្វះខាតបច្ចេកទេសកសិកម្ម ធនធានទឹកនិងថវិកា ។ ដោយហេតុនេះកសិករនៅក្នុងឃុំទាំងពីរគិតថាភាពងាយរងគ្រោះរបស់ពួកគេអាចកាត់បន្ថយបាន ដោយផ្តោតទៅលើវិស័យមួយចំនួនដូចជា :

-ផ្តល់លទ្ធភាពក្នុងការទទួលបាននូវគ្រាប់ពូជដែលបានកែលម្អ ។ ពូជទាំងនេះ គឺពូជដែលឆាប់បានទិន្នផល ធន់នឹងគ្រោះរាំងស្ងួតនិងទឹកជំនន់ ផ្តល់ទិន្នផលខ្ពស់និងមានតម្លៃថ្លៃ ។

-ផ្តល់សេវាកម្មផ្សព្វផ្សាយអំពីបច្ចេកទេសដាំស្រូវ និងដំណាំដទៃទៀត ការគ្រប់គ្រងសត្វចិញ្ចឹម និងវារីវប្បកម្ម

-ស្តារនិងកសាងនូវប្រព័ន្ធធារាសាស្រ្ត ជីកស្រះសហគមន៍ដែលអាចប្រើប្រាស់បានយូរ និងស្តារទំនប់ ប្រឡាយ ផ្លូវទឹកនិងបឹងធម្មជាតិនៅក្នុងឃុំ ។

# អក្សរកាត់

| | |
|---|---|
| AMK | អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា |
| CALM | តំបន់អភិរក្សតាមរយៈការគ្រប់តំបន់ទេសភាព |
| CARDI | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CC | ការប្រែប្រួលអាកាសធាតុ |
| CGA | អង្គការសកម្មភាពសកលកម្ពុជា |
| CHE | អង្គការអប់រំសុខភាពសហគមន៍ |
| CRC | កាកបាទក្រហមកម្ពុជា |
| CWS | អង្គការព្រះវិហារពិភពលោក |
| IFAD | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម |
| KAP | ចំណេះដឹង ឥរិយាបទ និងការអនុវត្ត |
| KIPD | វិទ្យាស្ថានខ្មែរសម្រាប់សន្តិភាពនិងការអភិវឌ្ឍ |
| LDCF | មូលនិធិប្រទេសអភិវឌ្ឍតិចតួច |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MAFF PSU | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពគាំទ្រគម្រោង |
| NAPA | ផែនការសកម្មភាពជាតិបន្សាំទៅនឹងការប្រែប្រួលអាកាធាតុ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NTFPs | អនុផលព្រៃឈើ |
| Oxfam | គណៈកម្មការអុកហ្វាមសម្រាប់ជំនួយគ្រោះអត់ឃ្លាន |
| PDA | មន្ទីរកសិកម្មខេត្ត |
| PADEK | អង្គការភាពជាដៃគូសម្រាប់ការអភិវឌ្ឍនៅកម្ពុជា |
| PDOE | មន្ទីរបរិស្ថានខេត្ត |
| PDORD | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| PDOP | មន្ទីរផែនការខេត្ត |
| PDOWA | មន្ទីរកិច្ចការនារីខេត្ត |
| PDOWRAM | មន្ទីរធនធានទឹកនិងឧត្តុនិយមខេត្ត |

| | |
|---|---|
| PFD | អង្គការភាពជាដៃគូសម្រាប់ការអភិវឌ្ឍ |
| RULIP | គម្រោងលើកកម្ពស់ជីវភាពជនបទ |
| SCUK | អង្គការសង្គ្រោះកុមារចក្រភពអង់គ្លេស |
| SGP | កម្មវិធីជំនួយខ្នាតតូច |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| VAHW | ភ្នាក់ងារសុខភាពសត្វភូមិ |
| VRA | វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ |
| WCS | អង្គការអភិរក្សសត្វព្រៃ |

# ២. សេចក្តីផ្តើម



*អ្នកភូមិប្រហែល ៣០០នាក់ ក្នុងខេត្តក្រចេះ និងព្រះវិហារបានចូលរួមក្នុងការសិក្សាវាយតម្លៃភាពរងគ្រោះពីការប្រែប្រួល-អាកាសធាតុ ។*

វិស័យកសិកម្មរួមវិភាគទានប្រមាណ ៣០% នៃផលិតផលក្នុងស្រុកសរុប (GDP) និងមានប្រជាពលរដ្ឋប្រមាណ ៨០% ចូលរួមនៅក្នុងវិស័យនេះ ។ ទោះបីយ៉ាងណាក៏ដោយការពឹងផ្អែកលើដំណាំស្រូវតែមួយមុខនិងកសិកម្មពឹងផ្អែកលើទឹកភ្លៀងបានធ្វើឱ្យវិស័យនេះ ងាយរងគ្រោះយ៉ាងខ្លាំងចំពោះការផ្លាស់ប្តូររបបទឹកភ្លៀង ដែលយើងរំពឹងថានឹងមានការកើនឡើងដោយសារការប្រែប្រួល-អាកាសធាតុ ។ នៅពេលបច្ចុប្បន្ននេះមានភស្តុតាងបង្ហាញថាជីវភាពរស់នៅដែលពឹងផ្អែកលើកសិកម្ម និងសន្តិសុខស្បៀងជាទូទៅនៅកម្ពុជា កំពុងត្រូវបានទទួលរងឥទ្ធិពលដោយសារការកើនឡើងនូវភាពញឹកញាប់និងភាពធ្ងន់ធ្ងរនៃទឹកជំនន់និងភាពរាំងស្ងួតដោយសារការប្រែប្រួលអាកាសធាតុ ។ គេទស្សន៍ទាយថាអ្នកក្រីក្រដែលមានជីវភាពរស់នៅពឹងផ្អែកលើកសិកម្ម នឹងរងការលំបាកខ្លាំងជាងគេដែលបណ្តាលមកពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ។

ឆ្លើយតបទៅនឹងបញ្ហាខាងលើគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹកនិងការប្រកបរបរកសិកម្ម ដែលជាគម្រោងទី១ចេញពីបញ្ជីអាទិភាពនៃកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា ។ គម្រោងនេះបាននឹងកំពុងអនុវត្តដោយអង្គភាពគាំទ្រគម្រោងនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ (MAFF/PSU) ក្រោមជំនួយឧបត្ថម្ភពីមូលនិធិសម្រាប់អភិវឌ្ឍន៍ប្រទេសក្រីក្រ (LDCF) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។ គម្រោងមានគោលបំណងកែលម្អសមត្ថភាពបន្សាំរបស់កសិករកម្ពុជាជនបទនៅក្នុងវិស័យកសិកម្មនិងធនធានទឹក តាមរយៈការកសាងសមត្ថភាពស្ថាប័នមូលដ្ឋានក្នុងការរៀបចំផែនការសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការធ្វើបង្ហាញលើយន្តការសមស្របបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងចងក្រងនូវមេរៀនបទពិសោធន៍សម្រាប់ការផ្សព្វផ្សាយ និងសម្រាប់ការពិភាក្សាគោលនយោ-បាយ ។ គម្រោងបាននឹងកំពុងអនុវត្តនៅក្នុងខេត្តដែលមានលក្ខខណ្ឌភូមិសាស្ត្រផ្ទុយគ្នាចំនួន២ គឺខេត្តព្រះវិហារដែលកសិករតែងជួបនូវ

គ្រោះរាំងស្ងួតញឹកញាប់ និងខេត្តក្រចេះដែលមានជំនន់កាន់តែញឹកញាប់ ។

ដើម្បីបានយល់ដឹងស៊ីជម្រៅអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើជីវភាពរស់នៅជនបទនៃខេត្តគោលដៅទាំង២ គម្រោងបានធ្វើការវាយតម្លៃភាពងាយរងគ្រោះ (VRA) នៅក្នុងខែសីហានិងកញ្ញា ឆ្នាំ២០១០។ VRA គឺជាឧបករណ៍វាយតម្លៃ ដោយមានការចូលរួមរៀបចំដោយកម្មវិធីជំនួយខ្នាតតូច (SGP) របស់ UNDP ។ វាអាចឱ្យកសិករលើកឡើងនូវគ្រោះភ័យ (Hazard) ដែលមានឥទ្ធិពលអវិជ្ជមានលើជីវភាពរស់នៅរបស់ពួកគេ និងដើម្បីកំណត់តម្រូវការអាទិភាពក្នុងការកាត់បន្ថយភាពងាយរងគ្រោះទាំងនេះ។ VRA ក៏ជាឧបករណ៍តាមដាននិងវាយតម្លៃផងដែរ ដែលផ្តល់អោយអ្នកអនុវត្តអាចវាយតម្លៃ ឥទ្ធិពលនៃសកម្មភាពរបស់ពួកគេក្នុង ការកាត់បន្ថយភាពងាយរងគ្រោះបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដោយផ្តល់ឱកាសឱ្យសហគមន៍ផ្តល់យោបល់ត្រឡប់ថាតើសកម្មភាពគម្រោងជួយកាត់បន្ថយហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងថាតើការអនុវត្តអាចត្រូវបានកែលម្អយ៉ាងដូចម្តេច? ការផ្តល់ឱកាសអោយអ្នកទទួលផលចូលរួមធ្វើ VRA បានជួយពង្រឹងអំណាចកសិករផងដែរដើម្បីទទួលយកភាពជាម្ចាស់និងគ្រប់គ្រងសកម្មភាពគម្រោងនៅថ្នាក់មូលដ្ឋាន។

ទោះបីជាការរៀបចំគម្រោងចាំបាច់ត្រូវបញ្ចូលនូវព័ត៌មាន និងបញ្ហាគន្លឹះដែលលើកឡើងនៅក្នុងដំណើរការ VRA នៅក្នុង-ករណីនេះការធ្វើ VRA ត្រូវបានធ្វើក្រោយគម្រោងត្រូវបានរៀបចំ។ ទោះជាយ៉ាងណាក៏ដោយ គោលបំណងនៃការធ្វើ VRA នេះគឺដើម្បី យកលទ្ធផលនៃការរកឃើញមកប្រើក្នុងការកំណត់សកម្មភាពគម្រោង ដើម្បីឆ្លើយតបផ្ទាល់ចំពោះតម្រូវការរបស់កសិករ។ ការធ្វើ VRA នេះ បានផ្តល់នូវសន្ទស្សន៍ភាពងាយរងគ្រោះឬទិន្នន័យគ្រឹះដែលអាចឱ្យអ្នកទទួលផលគម្រោងអាចវាស់វែង ប្រៀបធៀបជាមួយនឹងការរីកចម្រើន ចំពោះការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់គោលដៅ។

# ៣. គោលបំណងនិងវិធីសាស្ត្រ



*ការសិក្សានេះគឺចង់ដឹងពីស្ថានភាពបច្ចុប្បន្ននៃភាពងាយរងគ្រោះរបស់កសិករពីការប្រែប្រួលអាកាសធាតុ ដើម្បីកំណត់សកម្មភាពគម្រោងឆ្លើយតប ។*

## ៣.១ និយមន័យ VRA

VRA គឺជាឧបករណ៍មួយដែលវាស់វែងភាពងាយរងគ្រោះ និងសមត្ថភាពបន្សាំរបស់សហគមន៍មួយចំពោះការប្រែប្រួលអាកាសធាតុ។ ការវាស់វែងត្រូវបានធ្វើមុនសកម្មភាពគម្រោងចាប់ផ្តើមដើម្បីបង្កើតនូវទិន្នន័យគ្រឹះ ធ្វើម្តងទៀតនៅពាក់កណ្តាលគម្រោង ដើម្បីធ្វើការវាស់វែងការរីកចម្រើនដែលទទួលបានក្នុងការកាត់បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ និងនៅចុងគម្រោងដើម្បីវាស់វែងការផ្លាស់ប្តូរភាពងាយរងគ្រោះ និងសមត្ថភាពបន្សាំ ព្រមទាំងចងក្រងនូវមេរៀនបទពិសោធន៍ពីអន្តរាគមន៍នេះ ។

## ៣.២ គោលបំណង VRA

VRA ជាវិធីសាស្ត្រដែលមានការចូលរួម ដែលផ្តល់ដោយផ្ទាល់ដល់សមាជិកសហគមន៍នូវឥទ្ធិពលក្នុងការរៀបចំនិងកំណត់សកម្មភាពគម្រោង។ វាអាចបង្កើតនូវទិន្នន័យបែបគុណភាពនិងបរិមាណ ដែលអាចអោយគម្រោងឆ្លើយតបចំពោះអាទិភាពរបស់កសិករ និងអាចវាស់វែងការរីកចម្រើនបែបបរិមាណ នៅក្នុងការកាត់បន្ថយភាពងាយរងគ្រោះអាកាសធាតុ។ ចំពោះការរីកចម្រើនបែបលទ្ធផល ក្រុមការងារគម្រោងអាចសង្កេតមើលថាតើសកម្មភាពមួយណាអនុវត្តបានជោគជ័យ និងមួយណាមិនបានជោគជ័យ ហើយថាតើលទ្ធផលទាំងនេះបានរួមចំណែកទូលំទូលាយដល់សមិទ្ធិផលឬគោលបំណងគម្រោងដែរឬទេ?

ការធ្វើ VRA ត្រូវបានអនុវត្តជាច្រើនដំណាក់កាល :

### ក. ការរៀបចំកសិករ :

ដើម្បីរៀបចំក្រុមអ្នកទទួលផលគម្រោងអោយចូលរួមពេញលេញនៅក្នុងការធ្វើ VRA ការបង្កើនការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើង នៅខេត្តក្រចេះ នៅថ្ងៃទី៣ ខែសីហា និងនៅខេត្តព្រះវិហារ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០១០។ ការបង្កើនការយល់ដឹងនេះ ត្រូវបានធ្វើដើម្បីធានាថាកសិករយល់ដឹងច្បាស់លាស់ អំពីទស្សនៈទានស្តីពីការប្រែប្រួលអាកាសធាតុ និង-ថាតើការប្រែប្រួលអាកាសធាតុមានឥទ្ធិពលអ្វីខ្លះដល់ការរស់នៅរបស់ពួកគេ។

### ខ. ការបណ្តុះបណ្តាល VRA ដល់អ្នកសម្របសម្រួល :

ដំបូងបុគ្គលិកនិងដៃគូការងារគម្រោងពីមន្ទីរជំនាញនៅក្នុងខេត្តព្រះវិហារនិងខេត្តក្រចេះ ព្រមទាំងថ្នាក់ជាតិទទួលបានការបណ្តុះបណ្តាលស្តីពី VRA និងរំលឹកឡើងវិញអំពីការយល់ដឹងលើការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។ ដោយសារកម្មវិធីជំនួយខ្នាតតូចបានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់អង្គការដៃគូរក្រុមការងារគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ និងគម្រោងលើកកម្ពស់ជីវភាពរស់នៅតាមជនបទនៃមន្ទីរកសិកម្មនិងមន្ទីរធនធានទឹក ក៏បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនេះផងដែរ។ វគ្គនេះបានផ្តល់ផងដែរនូវការសម្របសម្រួលការអនុវត្តជាក់ស្តែងនៅក្នុងខេត្ត។

លើកទី២ វគ្គបណ្តុះបណ្តាលពេញមួយថ្ងៃបានប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែសីហាឆ្នាំ២០១០ ក្នុងខេត្តព្រះវិហារ ដែលមានអ្នក-សម្របសម្រួលគម្រោងចំនួន ៣៨នាក់ (ស្រី៧នាក់) បានចូលរួមរៀនសូត្រស្តីពីទស្សនៈទាននិងវិធីសាស្រ្ត VRA។ លើសពីនេះ អ្នក-សម្របសម្រួលក៏បានទទួលផងដែរនូវជំនាញសម្របសម្រួល ដើម្បីធានាថាពួកគេអាចសម្របសម្រួល និងទទួលបានព័ត៌មានពាក់ព័ន្ធពីអ្នកទទួលផលគម្រោង រួមទាំងក្រុមស្ត្រីដែលតែងតែមិនសូវបានលើកទឹកចិត្តឱ្យបញ្ចេញយោបល់នៅក្នុងការប្រជុំដោយមានការចូលរួម។ អ្នកសម្របសម្រួលរួមមាន បុគ្គលិកគម្រោងពីអង្គភាពគាំទ្រគម្រោង (MAFF/PSU) និងថ្នាក់ក្រោមជាតិរួមមានបុគ្គលិកមកពីគណៈកម្មាធិការប្រតិបត្តិខេត្ត មន្ទីរកសិកម្ម ធនធានទឹក កិច្ចការនារី និងមន្ទីរបរិស្ថាន ពីខេត្តព្រះវិហារ និងក្រចេះ។

នាពេលរសៀល អ្នកសម្របសម្រួលដែលបានទទួលការបណ្តុះបណ្តាលបានរៀបចំសំណួរនិងទម្រង់ហាស់ សម្រាប់ការចុះអនុវត្តជាក់ស្តែង។ អ្នកសម្របសម្រួល ត្រូវបានបែងចែកជាក្រុមតូចៗ ដែលមួយក្រុមមានសមាជិក ៣នាក់ ហើយក្រុមអ្នកសម្របសម្រួលនីមួយៗនឹងធ្វើការសម្របសម្រួលដំណើរការធ្វើ VRA ជាមួយកសិករ។ ពួកគេបានរៀបចំសំណួរជាភាសាខ្មែរដើម្បីប្រើនៅក្នុងដំណើរការអនុវត្តជាក់ស្តែង។ ដោយសារពុំមានពេលគ្រប់គ្រាន់ អ្នកសម្របសម្រួលមិនបានអនុវត្តសាកល្បងទេ ហេតុនេះពួកគេ-គិតទុកជាមុនថាអាចមានបញ្ហាខ្លះៗ ក្នុងការប្រើសំណួរពិភាក្សាដើម្បីប្រមូលព័ត៌មាន។

## គ. ការអនុវត្ត VRA ជាក់ស្តែង :

អ្នកសម្របសម្រួលដែលបានទទួលការបណ្តុះបណ្តាលធ្វើដំណើរទៅកាន់ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារនៅថ្ងៃបន្ទាប់នៃវគ្គបណ្តុះបណ្តាល ដើម្បីអនុវត្ត VRAជាក់ស្តែង។ រីឯការធ្វើ VRA នៅក្នុងឃុំបុសលាវ ខេត្តក្រចេះ បានប្រព្រឹត្តទៅនៅខែកញ្ញា ឆ្នាំ២០១០ សម្របសម្រួលដោយក្រុមការងារគម្រោងខេត្តក្រចេះ ពីមន្ទីរកសិកម្ម និងមន្ទីរធនធានទឹកខេត្ត។

នៅក្នុងឃុំទាំង២ ការណែនាំត្រូវបានធ្វើនិងគោលបំណងត្រូវបានពន្យល់ គឺដើម្បីរៀនសូត្រពីអ្នកភូមិអំពីឥទ្ធិពលបណ្តាលមកពីការប្រែប្រួលអាកាសធាតុទៅលើជីវភាពរស់នៅរបស់ពួកគេ សមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយលើការផ្លាស់ប្តូរអាកាសធាតុ និងអាទិភាពតម្រូវការ/ដំណោះស្រាយដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ដើម្បីឱ្យកសិករអាចចូលរួមបានប្រសើរនៅក្នុងការធ្វើ VRA វេទិកាសហគមន៍ស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងនាខែកន្លងទៅ។ ទោះបីយ៉ាងណាក៏ដោយ ការពន្យល់សង្ខេបរំលឹកឡើងវិញ ត្រូវបានធ្វើអំពីមូលហេតុនិងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ព្រមទាំងពាក្យសំខាន់ៗដែលនឹង ត្រូវប្រើនៅក្នុងការធ្វើ VRA ដូចជាពាក្យ ភាពងាយរងគ្រោះ សមត្ថភាពបន្សាំ ការបន្សាំ...។ ភូមិនីមួយៗត្រូវបានបែងចែកជាក្រុម ស្ត្រីនិងក្រុមបុរសដើម្បីធានា ថាសម្លេងរបស់ស្ត្រីនិងការចូលរួមរបស់ស្ត្រីបានពេញលេញ។

ឧបករណ៍សំខាន់ចំនួនពីរត្រូវបានណែនាំ និងប្រើប្រាស់សម្រាប់ការធ្វើ VRA :

## ៣.៣ ឧបករណ៍ VRA

ដើម្បីវាស់វែងការយល់ឃើញរបស់ប្រជាពលរដ្ឋអំពីការប្រែប្រួលអាកាសធាតុ និងបំពេញឱ្យទម្រង់ហាស់ ដែលត្រូវប្រើសម្រាប់វាស់វែងហានិភ័យអាកាសធាតុនាពេលបច្ចុប្បន្ននិងអនាគត ដើម្បីឱ្យគម្រោងបានយល់ដឹងថាតើប្រជាពលរដ្ឋបានកត់សម្គាល់ឃើញថាតើមានការផ្លាស់ប្តូរអាកាសធាតុដែរឬទេ និងជួយអ្នកសម្របសម្រួលអាចផ្តើមការពិភាក្សាទម្រង់ហាស់។ ឧទាហរណ៍តាមរយៈការវិភាគនិន្នាការ អ្នកសម្របសម្រួលគម្រោងអាចកំណត់បានថាភាពរាំងស្ងួត គឺជាការគំរាមកំហែងចម្បងនៅក្នុងឃុំទឹកក្រហម ហើយព្យុះ ជំនន់ និងភាពរាំងស្ងួតគឺជាការគំរាមកំហែងនៅក្នុងឃុំបុសលាវ ខេត្តក្រចេះ។

## ទម្រង់ហាស់

ជាឧបករណ៍ដែលត្រូវបានប្រើនៅក្នុងការសម្របសម្រួលធ្វើ VRA និងប្រមូលទិន្នន័យ (សូមមើលគំរូខាងក្រោម)។ នៅផ្នែកខាងឆ្វេងនៃទម្រង់ហាស់នេះគឺជាគំនិតកសិករទៅលើផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុមកលើជីវិតនិងជីវភាពរស់នៅរបស់ពួកគេ។ ចំណែកផ្នែកខាងស្តាំវិញ គឺជាកត្តាផ្សេងៗនិងហេតុផលនានាដែលអាចជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ បន្ទាប់ពីពិភាក្សារួចមក កសិករត្រូវបានស្នើឱ្យដាក់ពិន្ទុពី ១ ដល់ ៥។ ពិន្ទុ ១ សម្គាល់លើភាពងាយរងគ្រោះតិចតួចបំផុត និងពិន្ទុ ៥ មានន័យថាមានភាពងាយរងគ្រោះខ្លាំងជាងគេ។ បន្ទាប់ពីដាក់ពិន្ទុរួចហើយ អ្នកចូលរួមទាំងអស់ត្រូវបានស្នើឱ្យផ្តល់

ជាដំណោះស្រាយដើម្បីធ្វើឱ្យពិន្ទុប្រសើរជាងមុន។ លើសពីនេះ ទម្រង់ហាស់ចំនួន ៤ ផ្សេងៗគ្នា ត្រូវបានប្រើប្រាស់នៅក្នុងកិច្ចពិភាក្សា ដើម្បីប្រមូលព័ត៌មាន ទាក់ទងនឹងចំណុចផ្សេងៗនៃការប្រែប្រួលអាកាសធាតុរួមមានដូចខាងក្រោម :




សំណួរទី ១- តើមានញហាអ្វីខ្លះ កើតឡើង នៅពេលមានគ្រោះទឹកជំនន់ និងភាពរាំងស្ងួតម្តងៗ ?

សំណួរទី ២- តើមានបញ្ហាអ្វីខ្លះ កើតឡើង នៅពេលមានគ្រោះទឹកជំនន់ និងភាពរាំងស្ងួតកាន់តែធ្ងន់ធ្ងរជាងមុន ?

សំណួរទី ៣- តើមានកត្តាអ្វីខ្លះ ដែលជាឧបសគ្គដល់ការបន្សាំចំពោះបញ្ហាគ្រោះទឹកជំនន់ និងភាពរាំងស្ងួត ?

សំណួរទី ៤- តើអ្នក ឬសហគមន៍របស់អ្នកមានទំនុកចិត្តកម្រិតណាក្នុងការបន្តអនុវត្តក្រោយគម្រោងចប់ ?

## ៣.៤ ការដាក់ពិន្ទុ VRA

ទិន្នន័យបែបគុណភាព : ដើម្បីដាក់ពិន្ទុសម្រាប់សំណួរនីមួយៗកម្រិតពី១ ដល់ ៥ ត្រូវបានប្រើ ដែល១ ជាកម្រិតនៃភាពងាយរងគ្រោះទាបបំផុតនិង៥ជាកម្រិតនៃភាពងាយរងគ្រោះខ្ពស់បំផុត ។បន្ទាប់ពីពិភាក្សាអំពីឥទ្ធិពលបែបវិជ្ជមាននិងអវិជ្ជមានបណ្តាលមកពីការប្រែប្រួលអាកាសធាតុ កសិករត្រូវបានស្នើសុំឱ្យដាក់ពិន្ទុកម្រិតនៃភាពងាយរងគ្រោះរបស់ពួកគេដោយផ្អែកលើកម្រិតខ្នាតខាងលើសម្រាប់សំណួរនីមួយៗ។ ពិន្ទុមធ្យមភាគត្រូវបានកំណត់ដោយគុណពិន្ទុនីមួយៗជាមួយចំនួនអ្នកឆ្លើយ រួចចែកពិន្ទុសរុបជាមួយនឹងចំនួនអ្នកចូលរួមសរុបក្នុងក្រុមនីមួយៗ។ បន្ទាប់មក ពិន្ទុមធ្យមភាគរបស់ក្រុមស្ត្រីនិងបុរសត្រូវបានបូកបញ្ចូលគ្នារួចចែកជា២ ដើម្បីបានមធ្យមភាគ សម្រាប់សំណួរនីមួយៗនៃភូមិនីមួយៗ។ មធ្យមភាគនៃសំណួរនីមួយៗត្រូវបានបូកបញ្ចូលគ្នារួចចែកនឹងចំនួនសំណួរ (ចែកនឹង៣ដោយសារសំណួរទី៤ ត្រូវបានដកចេញ) ដើម្បីបានសន្ទស្សន៍ភាពងាយរងគ្រោះសម្រាប់ភូមិនីមួយៗ។ បន្ទាប់មកទៀត សន្ទស្សន៍នៃភូមិនីមួយៗត្រូវបានបូកបញ្ចូលគ្នា ហើយចែកនឹងចំនួនភូមិដែលបានចូលរួមក្នុងការធ្វើ VRA ដើម្បីបានសន្ទស្សន៍ភាពងាយរងគ្រោះរបស់ឃុំ។ សន្ទស្សន៍នៃភាពងាយរងគ្រោះរបស់ឃុំ បានក្លាយទៅជាទិន្នន័យគ្រឹះ ដែលនឹងត្រូវបានវាស់វែងក្នុងពេល

បន្ទាប់នៅពាក់កណ្ដាលគម្រោង ដើម្បីពិនិត្យមើលការរីកចម្រើនដែលទទួលបានក្នុងការកាត់បន្ថយភាពងាយរងគ្រោះ ។

ទិន្នន័យបែបបរិមាណ ៖ ទិន្នន័យបែបបរិមាណរួមមានព័ត៌មានទាំងអស់ដែលប្រមូលបានក្នុងអំឡុងពេលពិភាក្សា ហើយត្រូវបានចាត់ថ្នាក់តាមផ្នែកផ្សេងៗនៃ ទម្រង់ហាស់ (សូមមើលរូបភាពខាងលើ) ។ ទិន្នន័យទាំងនេះរួមមាន ៖

- ឥទ្ធិពលអវិជ្ជមាន
- ឥទ្ធិពលវិជ្ជមាន
- ឧបសគ្គចំពោះការបន្សាំ
- សំណើដំណោះស្រាយ

## ៣.៥ ការឆ្លុះបញ្ចាំងការធ្វើ VRA

នាថ្ងៃបន្ទាប់នៃការធ្វើ VRA នៅក្នុងខេត្តព្រះវិហារ អ្នកសម្របសម្រួលបានពិភាក្សាពីបញ្ហាប្រឈមដែលពួកគេជួបប្រទះនៅក្នុងអំឡុងពេលធ្វើ VRA និងថាតើបញ្ហាទាំងនេះអាចត្រូវបានកែលម្អដូចម្ដេច ជាពិសេសសម្រាប់ខេត្តក្រចេះដែលមិនទាន់បានអនុវត្តនៅឡើយ ។ បញ្ហាប្រឈមត្រូវបានកត់ត្រានៅក្នុងផ្នែកមេរៀនបទពិសោធន៍នៃចុងបញ្ចប់របស់របាយការណ៍នេះ ។

## ៣.៦ ការវិភាគទិន្នន័យ

ដាជាងវិភាគទិន្នន័យតាមភូមិនីមួយៗ ការញែកចម្លើយសម្រាប់សំណួរនីមួយៗត្រូវបានប្រមូលដោយដាក់ចម្លើយ ដែលបានឆ្លើយញឹកញាប់ជាតំណាងទស្សនៈរបស់អ្នកចូលរួមភាគច្រើន ។ ក្នុងន័យនេះ ចម្លើយដែលបានផ្ដល់ដោយកសិករ ១ ឬ២នាក់ ត្រូវបានគិតថាមិនមែនចម្លើយដែលអាចតំណាងទស្សនៈទូទៅរបស់ឃុំឡើយ ។ ទោះបីយ៉ាងណាក៏ដោយ ចម្លើយដែលមិនបានពិភាក្សានៅក្នុងរបាយការណ៍នេះអាចនៅតែត្រូវបានប្រើប្រាស់ដោយគម្រោង នៅពេលឆ្លើយតបតម្រូវការជាក់លាក់របស់ភូមិ ។

## ៣.៧ ភាពទុកចិត្តបាននៃការរកឃើញ

ក្រុមនីមួយៗមានអ្នកសម្របសម្រួលផ្សេងៗគ្នា ហើយ VRA ត្រូវបានធ្វើដំណាលគ្នា ដូច្នេះលទ្ធផលទទួលបានដោយឡែកៗពីគ្នា ។ លើសពីនេះ ក្រុមការងារគម្រោងបានស្វែងរកការបញ្ជាក់លើលទ្ធផលដែលមិនច្បាស់ឬជាក់លាក់នៅថ្ងៃក្រោយទៀត ។ ចម្លើយប្រហាក់ប្រហែលគ្នារវាងក្រុមបុរសនិងក្រុមស្ត្រីនៅក្នុងឃុំ ត្រូវមើលឃើញថា ជាចំណុចឆ្លុះបញ្ចាំងអំពីបញ្ហានៃការប្រែប្រួលដែលបានជួបប្រទះដោយអ្នកភូមិនៅក្នុងឃុំជាមួយគ្នា ។ ចម្លើយផ្សេងគ្នារវាងឃុំបុសលាវ និងទឹកក្រហមបានឆ្លុះបញ្ចាំងការប្រែប្រួលអាកាសធាតុផ្អែកលើទីតាំងភូមិសាស្ត្រ ។ ទោះបីយ៉ាងណាក៏ដោយ គេបានកត់ចំណាំថាគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ កំពុងត្រូវបានអនុវត្តក្នុងភាពជាដៃគូ ជាមួយគម្រោងលើកកម្ពស់ជីវភាពរស់នៅតាមជនបទដែលគាំទ្រដោយ UNDP/IFAD (RULIP) ដែលផ្ដោតលើការកែលម្អជីវភាពរស់នៅតាមរយៈកសិកម្ម ។ គម្រោង RULIP បានប្រតិបត្តិនៅក្នុងតំបន់គោលដៅមួយចំនួនរបស់គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ រួចទៅហើយ ។ ជាលទ្ធផលវាមានលទ្ធភាពខ្ពស់ ដោយសារចម្លើយ ដែលផ្ដល់ឱ្យដោយកសិករវាមានទំនោរទៅរកសកម្មភាពដែលកំពុងបានធ្វើដោយគម្រោង RULIP ។

# ៤. ការរកឃើញនៅក្នុងឃុំទឹកក្រហម ខេត្តព្រះវិហារ




*ខេត្តព្រះវិហារជួបប្រទះគ្រោះរាំងស្ងួតញឹកញាប់ ដែលជះឥទ្ធិពលអវិជ្ជមានដល់វិស័យកសិកម្ម ធនធានទឹក និងសុខភាពមនុស្សសត្វជាដើម ។*

## ៤.១ សាវតា

ឃុំទឹកក្រហមស្ថិតនៅក្នុងស្រុកជាំក្សាន្ត ។ ឃុំមានប្រជាជនសរុបប្រមាណ ៨៥៤នាក់ ។ ឃុំមានភូមិចំនួន ៦ គឺភូមិ ទឹកក្រហម អូរក្សាន្ត សង្គមថ្មី ចាត់តាំង ត្រពាំងធំ និងរបុញ ។ ប្រជាពលរដ្ឋ ៨៨នាក់ (ស្ត្រី៤១នាក់) មកពីភូមិ ចំនួន៥បានចូលរួមនៅក្នុងការធ្វើ VRA ដែលតំណាងឱ្យ ១%នៃប្រជាពលរដ្ឋឃុំទឹកក្រហមទាំងមូល ។

## ៤.២ ការវិភាគនិន្នាការ និងប្រភេទហានិភ័យនៃការប្រែប្រួលអាកាសធាតុ

មុនពេលធ្វើ VRA ការវិភាគនិន្នាការត្រូវបានធ្វើ ដើម្បីប៉ាន់ប្រមាណមើលថាតើប្រជាពលរដ្ឋបានកត់សម្គាល់នូវការផ្លាស់ប្តូរអាកាសធាតុនៅក្នុងអំឡុងពេលមួយ និងកំណត់ផងដែរគ្រោះភ័យនៃការប្រែប្រួលអាកាសធាតុណាមួយដែលបានប៉ះពាល់ប្រជាពលរដ្ឋបំផុតនៅក្នុងឃុំទឹកក្រហម ។ ហានិភ័យនៃការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់ជីវិតនិងជីភាពរស់នៅរបស់ពួកគេ រួមមានគ្រោះរាំងស្ងួតនិងទឹកជំនន់ ។ ការវិភាគនិន្នាការបានកំណត់ភាពរាំងស្ងួតជាការគំរាមកំហែងចម្បងមួយចំពោះជីវភាពរស់នៅហើយជាលទ្ធផល VRA ត្រូវបានធ្វើដោយផ្តោតលើគ្រោះរាំងស្ងួតនៅក្នុងឃុំ ។

គ្រោះទឹកជំនន់ : ស្ត្រីដែលចូលរួមភាគច្រើនកត់សម្គាល់ថា ចំនួនគ្រោះទឹកជំនន់នៅក្នុងភូមិគោលដៅមានកម្រិតថេរឬថយចុះចាប់តាំងពីតាំងពីទសវត្សរ៍ ៨០មក ។ បុរសនៅក្នុងភូមិត្រពាំងធំ អូរក្សាន្ត និងឃុំទឹកក្រហមគិតថាចំនួនគ្រោះទឹកជំនន់បានកើនឡើងជាងមុន ក៏ប៉ុន្តែបុរសនៅក្នុងភូមិដទៃទៀតគិតថាចំនួនគ្រោះទឹកជំនន់មានកម្រិតថេរឬថយចុះ ។ តាមពិតកសិករជាទូទៅពុំបានកត់សម្គាល់ពីការកើនឡើងនៃចំនួន គ្រោះទឹកជំនន់ ក្នុងអំឡុងពេល៣០ឆ្នាំចុងក្រោយនេះឡើយ ក៏ប៉ុន្តែទឹកជំនន់វិញ បានប៉ះពាល់

អវិជ្ជមានដល់ជីវភាពរបស់ពួកគេ ដោយបំផ្លាញដំណាំជាដើម ។ កសិករនៅក្នុងតំបន់នេះបានសង្កេតឃើញថា គ្រោះទឹកជំនន់បានបំផ្លាញផលដំណាំរបស់ពួកគេយ៉ាងធ្ងន់ធ្ងរ និងជាប្រចាំក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ លើសពីនេះ គ្រោះទឹកជំនន់ក៏បានបំផ្លាញនូវផ្លូវថ្នល់និងប្រព័ន្ធធារាសាស្ត្រ ដូចដែលបានកើតឡើងនៅពេលមានខ្យល់ព្យុះកេតសាណា ដែលបានបំផ្លាញប្រព័ន្ធធារាសាស្ត្រនៅក្នុងឃុំទឹកក្រហម ។

គ្រោះរាំងស្ងួត : ក្រុមបុរសនិងស្ត្រីនៅក្នុងភូមិគោលដៅទាំងអស់បានសង្កេតឃើញថា គ្រោះរាំងស្ងួតបានកើតឡើងញឹកញាប់និងមានរយៈពេលយូរជាងមុន នៅក្នុងរយៈពេល ៣០ឆ្នាំចុងក្រោយនេះ ។ ចំណែកឯឥទ្ធិពល របស់វាមកលើផលដំណាំក៏មានសភាពធ្ងន់ធ្ងរផងដែរ ។ ហេតុដូច្នេះ កសិករនៅគ្រប់ភូមិទាំងអស់បានដាក់ពិន្ទុខ្ពស់បំផុតទៅលើឥទ្ធិពលរបស់គ្រោះរាំងស្ងួតមកលើផលដំណាំនៅក្នុងអំឡុង ៥ឆ្នាំចុងក្រោយនេះ ហើយនេះគឺដោយសារតែពួកគេបានជួបប្រទះនូវគ្រោះរាំងស្ងួតនៅដើមរដូវវស្សានាឆ្នាំ ២០១០ ។

## ៤.៣ ហានិភ័យនៃការប្រែប្រួលអាកាសធាតុនៅក្នុងឃុំទឹកក្រហម

សំណួរទី ១- តើអ្នកជួបប្រទះបញ្ហាអ្វីខ្លះ នៅពេលមានភាពរាំងស្ងួត? តើវាប៉ះពាល់ដល់ការរស់នៅរបស់អ្នកដូចម្តេចខ្លះ?

ផ្អែកលើលទ្ធផលចម្លើយដែលផ្តល់ឱ្យដោយក្រុមស្រ្តីនិងបុរស ពុំមានភាពខុសគ្នាខ្លាំងទេ ។ ផ្នែក៦ (តាមលំដាប់នៃភាពសំខាន់) ត្រូវបានកំណត់ ដែលមានឥទ្ធិពលខ្លាំងដោយសារការប្រែប្រួលអាកាសធាតុ ជាពិសេសដោយគ្រោះរាំងស្ងួត និងការអូសបន្លាយនៃភាពរាំងស្ងួត :

១. ឥទ្ធិពលអវិជ្ជមាន លើសុខភាពសត្វ

២. ការខូចខាតស្រូវ ធ្វើឱ្យទិន្នផលធ្លាក់ចុះ

៣.ឥទ្ធិពលអវិជ្ជមានលើធនធានទឹក

៤. ឥទ្ធិពលអវិជ្ជមានលើសុខភាពមនុស្ស

៥. ខូចខាតដំណាំដទៃទៀត

៦. ខូចហេដ្ឋារចនាសម្ព័ន្ធ

## រូបភាព ៤.១ ៖ តារាងសង្ខេបនៃចម្លើយដែលឆ្លើយញឹកញាប់សម្រាប់សំណួរទី១




ដូចបានបង្ហាញនៅក្នុងរូបភាពខាងលើ ក្រុមបុរសនិងស្ត្រីក្នុងភូមិទាំង៥ បានមើលឃើញការប្រែប្រួលអាកាសធាតុ បង្កើតនូវការគំរាមធំជាងគេចំពោះសត្វពាហនៈ ។ តើឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុមានលើសត្វពាហនៈមានកម្រិតណានោះ ពុំបានលើកឡើងច្បាស់ទេនៅក្នុងដំណើរការ VRA ។ ទោះបីយ៉ាងណាក៏ដោយការពិភាក្សាបន្ត បានបង្ហាញថានៅពេលដែលធាតុអាកាសក្តៅខ្លាំង សត្វចាប់ផ្តើមឈឺនិងងាប់ ដោយជម្ងឺញ៉ូវកាសចំពោះមាន់ អ៊ុតក្តាម បូសខ្យល់ចំពោះគោនិងក្របី ។ ផ្នែកដែលប៉ះពាល់ខ្លាំងជាងគេទី២ ដោយភាពរាំងស្ងួត គឺលើដំណាំស្រូវ ។ ការខូចខាតរួមមាន ក្រៀមសំណាប ស្រូវស្កកដោយសារខ្វះទឹក ដែលនាំឱ្យកសិករទទួលបានទិន្នផលទាប ។ គ្រោះរាំងស្ងួត ក៏បានធ្វើឱ្យខូចខាតដល់ដំណាំដទៃទៀតផងដែរ ហើយការខូចខាតនេះត្រូវបានគេឱ្យចំណាត់ថ្នាក់ទី៥ ។

ផ្នែកទី៣និងទី៤ គឺឥទ្ធិពលអវិជ្ជមានលើសុខភាពមនុស្សនិងធនធានទឹក ដែលនិយាយអំពីតំបន់ប្រព័ន្ធធារាសាស្ត្រ ស្រះនិង-អណ្តូងសហគមន៏ ដែលតែងតែរីងហួតនៅក្នុងឆ្នាំដែលមានភាពរាំងស្ងួត ។ អណ្តូងនិងស្រះសហគមន៏ដើរតួយ៉ាងសំខាន់នៅក្នុងការផ្គត់ផ្គង់ទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារនៅពេលដែលប្រភពទឹកដទៃទៀត ត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រពដំណាំនិងសត្វពាហនៈ ។ ឥទ្ធិពលលើសុខភាពមនុស្សគឺសម្តៅលើបញ្ហាឈឺពោះនិងរាគរូស ដែលអាចបណ្តាលមកពីការធ្លាក់ចុះនូវគុណភាពទឹកដោយសារប្រភពទឹកស្អាតត្រូវបានរីងស្ងួតក្នុងអំឡុងពេលគ្រោះរាំងស្ងួតនិងរដូវប្រាំង ។ ផ្នែកទី៦ គឺការខូចខាតហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងជំនន់ ជាជាងជាមួយគ្រោះរាំងស្ងួត ។ កសិករបង្ហាញថា ទឹកជំនន់ធ្វើអោយខូចខាតផ្លូវនិងទំនប់ធារាសាស្ត្រ ដូចភស្តុតាងបានបង្ហាញចំពោះទំនប់ធារាសាស្ត្រ ធុនមធ្យម *ទំនប់អូរក្សាន្ត* នៅក្នុងឃុំទឹកក្រហម ដែលបានបំផ្លាញដោយព្យុះកេតសាណា ឆ្នាំ២០០៩ ។

ទម្រង់ហាស់ខាងក្រោមបង្ហាញអំពីចម្លើយរួមសរុបបញ្ចូលគ្នា ដែលបានផ្តល់អោយដោយក្រុមបុរសនិងស្ត្រីពីភូមិទាំង៥ ។ នៅផ្នែកខាងឆ្វេងបង្ហាញអំពីចម្លើយ អវិជ្ជមានដែលទាក់ទងថាតើការប្រែប្រួលអាកាសធាតុ ប៉ះពាល់ប្រជាពលរដ្ឋយ៉ាងដូចម្តេច រីឯខាងស្តាំបង្ហាញការឆ្លើយតបវិជ្ជមាន ។ ការឆ្លើយតបវិជ្ជមាន គឺប្រមូលនូវទស្សនៈ របស់កសិករចំពោះអ្វីដែលមានស្រាប់នៅក្នុងភូមិរបស់

ពួកគេ ដែលជួយឱ្យពួកគេអាចលៃលកដោះស្រាយជាមួយការប្រែប្រួលអាកាសធាតុ។

| ហេតុផលសម្រាប់ចម្លើយអវិជ្ជមាន | សំណួរទី១ | ហេតុផលសម្រាប់ចម្លើយវិជ្ជមាន |
|---|---|---|
| ១. ឥទ្ធិពលលើធនធានទឹក សម្រាប់កសិកម្ម និងប្រើប្រាស់ក្នុងគ្រួសារ។<br>២. ខូចសំណាប ស្រូវ និងដំណាំរួមផ្សំ ដោយសារជំនន់ រាំងស្ងួត និងសត្វល្អិតបំផ្លាញ។<br>៣. ប៉ះពាល់សុខភាពមនុស្ស។<br>៤. ប៉ះពាល់សុខភាពសត្វ។<br>៥. ខូចខាតហេដ្ឋារចនាសម្ព័ន្ធ (ទំនប់និងផ្លូវ)។<br>៦. ពុំមានពូជស្រូវដាំដុះឡើងវិញបន្ទាប់ពីរាំងស្ងួតឬជំនន់។<br>៧. ខ្វះជំនាញកសិកម្មដើម្បីសម្របខ្លួនជាមួយឥទ្ធិពល។ | តើអ្នកជួបប្រទះបញ្ហាអ្វីខ្លះ នៅពេលមានភាពរាំងស្ងួត? តើវាប៉ះពាល់ដល់ការរស់នៅរបស់អ្នកដូចម្តេចខ្លះ?<br>ពិន្ទុ<br>៤<br><br>តើអាចកែលម្អយ៉ាងដូចម្តេច?<br>១. ជួសជុលឬសាងសង់ទំនប់ និងជីកស្រះសម្រាប់ការស្រោចស្រពនៅពេលរាំងស្ងួត។<br>២. ផ្តល់វគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីដំណាំនិងបន្លែ។<br>៣. ផ្តល់ពូជស្រូវស្រាល ទិន្នផលខ្ពស់ និងធន់ទ្រាំនឹងរាំងស្ងួត។<br>៤. ស្តារអណ្តូងសម្រាប់ទឹកផឹក និងកែលម្អលទ្ធភាពទទួលបានសេវាសុខភាពសត្វ។ | ១.មានមណ្ឌលសុខភាពស្រុក។<br>២. ភូមិមួយចំនួនមានអណ្តូង។<br>៣.មានទំនប់ធារាសាស្ត្រចាស់។<br>៤. មានភ្នាក់ពេទ្យសត្វភូមិ។<br>៥. ភូមិខ្លះមានប្រព័ន្ធធារាសាស្ត្រ/ស្រះ។<br>៦. ភូមិខ្លះបានទទួលការគាំទ្រពីគម្រោង RULIP អង្គការ CWS និងមន្ទីរពាក់ព័ន្ធខេត្ត អំពីការរៀបចំសួនបន្លែគ្រួសារ សុខភាពសត្វ ពេទ្យសត្វ និងការជីកអណ្តូង។ |

នៅផ្នែកកណ្តាលបង្ហាញថាពិន្ទុ VRA សម្រាប់សំណួរទី១ គឺ៤ នៅកម្រិតពិន្ទុពី១ ដល់ ៥។ នៅពីក្រោមពិន្ទុ ទម្រង់ហាស់បង្ហាញពីគំនិតរបស់កសិករថាតើពិន្ទុ៤ ខាងលើអាចកែលម្អបានយ៉ាងដូចម្តេច? ផ្នែកនេះផ្តល់អោយកសិករនូវសម្លេងថាតើសកម្មភាពគម្រោងត្រូវបានរៀបចំដូចម្តេចដើម្បីឆ្លើយតបចំពោះឥទ្ធិពលអវិជ្ជមានបណ្តាលមកពីការប្រែប្រួលអាកាសធាតុបង្ហាញនៅផ្នែកខាងឆ្វេងដៃក្នុងទម្រង់ហាស់។

សំណួរទី២ : តើមានអ្វីកើតឡើង ប្រសិនបើគ្រោះរាំងស្ងួតញឹកញាប់ទ្វេរដង? តើវាប៉ះពាល់អ្នកនិងសហគមន៍របស់អ្នកយ៉ាងដូចម្តេច?

សំណួរទី២ ព្យាយាមកំណត់ថាតើការរស់នៅនិងជីវភាពរស់នៅនឹងទទួលរងឥទ្ធិពលយ៉ាងដូចម្តេច ប្រសិនបើមានការកើនឡើងនូវគ្រោះថ្នាក់ និងភាពញឹកញាប់នៃគ្រោះភ័យអាកាសធាតុ។ ផ្អែកលើការវិភាគនិន្នាការ សំណួរទី២ផ្តោតលើឥទ្ធិពលដែលអាចកើត-

មាន ដោយសារការកើននូវគ្រោះរាំងស្ងួត។ ផ្អែកលើតារាងខាងក្រោម ចម្លើយមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងចម្លើយក្នុងសំណួរទី១។ នៅក្នុងលំដាប់នៃភាពសំខាន់ កសិករមានអារម្មណ៍ថាការកើននូវគ្រោះរាំងស្ងួតនឹងមានឥទ្ធិពលអវិជ្ជមាន លើផ្នែកនានា-ដូចខាងក្រោម :

១. ឥទ្ធិពលអវិជ្ជមានលើសុខភាពសត្វ

២. ទិន្នផលស្រូវកាន់តែថយចុះ

៣. កាន់តែខ្វះខាតទឹក

៤. ប្រជាពលរដ្ឋកាន់តែជួបកង្វះខាតស្បៀងកាន់តែខ្លាំង

៥. ឥទ្ធិពលអវិជ្ជមានលើសុខភាពមនុស្ស

៦. កាត់បន្ថយចំណូល

កសិករនៅឃុំទឹកក្រហមគិតថាការកើនឡើងនៃឥទ្ធិពលនៃគ្រោះរាំងស្ងួតនឹងប៉ះពាល់យ៉ាងខ្លាំងដល់សត្វក្នុងកម្រិតខ្ពស់បំផុត។ បន្ទាប់ពីសត្វ គឺកសិករខ្វល់ខ្វាយអំពីទិន្នផលស្រូវនិងទឹក។ ចុងក្រោយកសិករបានបង្ហាញថា គ្រោះរាំងស្ងួតកាន់តែច្រើន នឹងនាំមកនូវទិន្នផលទាប និងលទ្ធភាពរបស់ពួកគេក្នុងការផលិតស្រូវគ្រប់គ្រាន់សម្រាប់ហូប។ ការសង្កត់ធ្ងន់លើស្រូវ ពីព្រោះថាស្រូវគឺជាអាហារប្រចាំថ្ងៃសម្រាប់អ្នកភូមិទាំងអស់ និងសម្រាប់ប្រជាជនកម្ពុជាទាំងមូល។ ផ្ទុយពីស្រូវមានតែភូមិមួយប៉ុណ្ណោះដែលបានលើកឡើងថា មានការខូចខាតដំណាំរួមផ្សំផ្សេងៗទៀត។

## រូបភាព ៤.២ : ឥទ្ធិពលនៃកំណើនការប្រែប្រួលអាកាសធាតុ



ទាក់ទងទៅនឹងឥទ្ធិពលលើធនធានទឹក កសិករមើលឃើញថាធនធានទឹកកាន់តែរីងស្ងួត ជាលទ្ធផលធ្វើឱ្យខ្វះទឹកសម្រាប់សត្វនិងការស្រោចស្រព។ កសិករខ្លះបានបង្ហាញថាកង្វះទឹកស្អាតប្រើប្រាស់ក៏បានក្លាយជាបញ្ហាមួយផងដែរ ដោយសារគុណភាពទឹកធ្លាក់ចុះដោយសារការកើនឡើងនូវភាពរាំងស្ងួត។ នៅក្នុងភូមិសង្គមថ្មី កសិករមានអារម្មណ៍ផងដែរថា ការកើនឡើងនូវភាពរាំងស្ងួតអាចនាំឱ្យមានទំនាស់ទាក់ទង នឹងការប្រើប្រាស់ទឹក។

ឥទ្ធិពលដែលអាចកើតឡើងដោយសារកំណើននៃភាពរាំងស្ងួតលើសុខភាពមនុស្សនិងសុវត្ថិភាពស្បៀង គឺបណ្តាលមកពីការចុះថយទិន្នផលដែលអាចកំណត់ពិន្ទុដូចគ្នា។ អសន្តិសុខស្បៀងនិងការថយចុះនូវចំណូល គឺជាលទ្ធផលមួយនៃឥទ្ធិពលដែលថែមលើគ្នានៃការកើនឡើងនូវភាពរាំងស្ងួត។ កសិករបង្ហាញថា ការកាត់បន្ថយចំណូលនិងអសន្តិសុខស្បៀង នឹងអាចប៉ះពាល់ដល់លទ្ធភាពចិញ្ចឹមជីវិតរបស់ពួកគេ និងការបញ្ជូនកូនទៅសាលារៀន។ ស្ត្រីនៅក្នុងភូមិចាត់តាំងនិងទឹកក្រហមបានលើកឡើងថា បើសិនគ្រោះរាំងស្ងួតកើនឡើង អ្នកភូមិអាចធ្វើចំណាកស្រុកទោះបីពួកគេមិនបាននិយាយថាពួកគេនឹងទៅកាន់ទីណាក៏ដោយ។

| ហេតុផលសម្រាប់ចម្លើយអវិជ្ជមាន | សំណួរទី២ | ហេតុផលសម្រាប់ចម្លើយវិជ្ជមាន |
|---|---|---|
| ១. សត្វកាន់តែឈឺច្រើន។<br>២. ឥទ្ធិពលអវិជ្ជមានកាន់តែច្រើនលើសុខភាពមនុស្ស។<br>៣. ខ្វះអាហារ និងអត់ឃ្លាន។<br>៤. ខ្វះទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ សត្វ និងស្រោចស្រព។<br>៥. ការខូចស្រូវកើនឡើង និងទិន្នផលចុះទាប។<br>៦. អ្នកភូមិអាចធ្វើចំណាកស្រុក។<br>៧. ខ្វះទឹកស្អាតប្រើប្រាស់។ | តើអ្នកជួបប្រទះបញ្ហាអ្វីខ្លះ នៅពេលមានភាពរាំងស្ងួតកើនឡើងទ្វេរដង? តើវាប៉ះពាល់ដល់ការរស់នៅរបស់អ្នកដូចម្តេចខ្លះ?<br>ពិន្ទុ<br>៤.៤៨<br><br>តើអាចកែលម្អយ៉ាងដូចម្តេច?<br>១. ជួសជុល ឬសាងសង់ទំនប់។<br>២. ផ្តល់ពូជស្រូវស្រាល ទិន្នផលខ្ពស់ និងធន់ទ្រាំនឹងរាំងស្ងួត។<br>៣. ផ្តល់វគ្គបណ្តុះបណ្តាលការចិញ្ចឹមសត្វ។<br>៤. ផ្តល់វគ្គបណ្តុះបណ្តាលអំពីប្រពលវប្បកម្មដំណាំ និងបន្លែ។<br>៥. ដាំដើមឈើឡើងវិញ។ | ១. អាចប្រមូលអនុផលព្រៃឈើ (ផ្សិត ទំពាំង ផ្តៅ ផ្លែឈើ..)។<br>២. មានការគាំទ្រពីភាគបាទក្រហម រដ្ឋាភិបាល និងអង្គការ។<br>៣. មានអណ្តូងជីកមួយចំនួន។<br>៤. អាចដាំដំណាំរួមផ្សំមួយចំនួន។ |

បើតាមទម្រង់ហាស់ខាងលើ កសិករនៅក្នុងទឹកក្រហមមានអារម្មណ៍ថាកម្រិតនៃភាពងាយរងគ្រោះបច្ចុប្បន្នរបស់ពួកគេគឺ៤ (ពិន្ទុ VRA ទី១) ហើយវាអាចកើនដល់ ៤.៤៨ ប្រសិនបើគ្រោះរាំងស្ងួតកើនឡើង ដោយសារការប្រែប្រួលអាកាសធាតុ ។

សំណួរទី៣ : តើអ្វីខ្លះជាឧបសគ្គសម្រាប់អ្នក ក្នុងការបន្សាំទៅនឹងកំណើនគ្រោះរាំងស្ងួត? តើអ្នកនិងសហគមន៍របស់អ្នកមានមធ្យោបាយអ្វីខ្លះសម្រាប់គ្រប់គ្រងបញ្ហានានាទាំងនេះ ដែលកើតមានកាន់តែញឹកញាប់?

ឧបសគ្គចម្បងៗរួមមាន :

១. កង្វះធនធានទឹក

២. កង្វះប្រាក់

៣. កង្វះបច្ចេកទេសកសិកម្ម

៤. កង្វះព័ត៌មាន

៥. កង្វះការគាំទ្រខាងស្ថាប័ន

មិនដូចសំណួរទី១ និងទី២ឡើយ ចម្លើយអំពីឧបសគ្គដែលរារាំងកសិករពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មិន-សូវដូចគ្នាឡើយ ។ ទោះជាយ៉ាងណាក៏ដោយ កង្វះទឹកត្រូវបានអ្នកភូមិភាគច្រើនមើលឃើញថាជាឧបសគ្គធំបំផុតសម្រាប់ការបន្សាំ ។ កង្វះធនធានទឹកសម្រាប់ប្រព័ន្ធស្រោចស្រព ទំនប់និងស្រះតាមគ្រួសារត្រូវបានមើលឃើញថាជារបាំងដ៏ចម្បងដែលរារាំងកសិករពីការពុះពារនៅក្នុងផលិតកម្មកសិកម្ម ដើម្បីតទល់នឹងការប្រែប្រួលអាកាសធាតុ ។ វត្តមានទឹកអាចឱ្យកសិករស្រោចស្រពស្រែ នៅពេលដែលមានគ្រោះរាំងស្ងួត បណ្តាលពីកូនរដូវប្រាំង ហើយក៏អាចឱ្យពួកគេដាំបន្លែនៅរដូវប្រាំងនិងសម្រាប់ការចិញ្ចឹមសត្វផងដែរ ។

## រូបភាព ៤.៣ : ឧបសគ្គចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ



កង្វះប្រាក់ត្រូវបានកសិករជាទូទៅលើកឡើងថាជាឧបសគ្គធំទីពីរនៅក្នុងការពុះពារទល់នឹងការប្រែប្រួលអាកាសធាតុ ។ កសិករបានបង្ហាញថាពួកគេខ្វះប្រាក់ដើម្បីទិញគ្រាប់ពូជនៅពេលដែលដំណាំរបស់ពួកគេត្រូវបំផ្លាញ ដើម្បីសង់អាងសម្រាប់ត្រងទឹកទុក ដើម្បីទ្រទ្រង់ការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេ និងបញ្ជូនកូនទៅសាលារៀន ។ ជាសំណាងអាក្រក់ ចម្លើយភាគច្រើនអំពីកង្វះប្រាក់ថាជាឧបសគ្គចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មិនបានពង្រីកដើម្បីផ្តល់គំនិតដែលទាក់ទងនឹងថាតើប្រាក់នោះនឹងអាចយកទៅប្រើប្រាស់បែបណា ដើម្បីពុះពារទល់នឹងការប្រែប្រួលអាកាសធាតុ ។

ក្រុមចំនួនប្រាំមួយក្នុងចំណោមក្រុមទាំងដប់ក៏ចាប់អារម្មណ៍អំពីកង្វះជំនាញ និងចំណេះដឹងអំពីបច្ចេកទេសកសិកម្ម កង្វះព័ត៌មាននិងការគាំទ្រខាងស្ថាប័ន ថាជាឧបសគ្គចំពោះការបន្សាំផងដែរ ។ កង្វះការអនុវត្តកសិកម្ម រាប់បញ្ចូលបច្ចេកទេសរបៀបធ្វើស្រែឱ្យបានប្រសើរជាងមុន របៀបដាំដំណាំផ្សេងទៀតដូចជាបន្លែនិងឈើហូបផ្លែ បច្ចេកទេសចិញ្ចឹមសត្វនិងវារីវប្បកម្ម ។ ទាក់ទងនឹងព័ត៌មានចម្លើយមិនបានផ្តល់ភាពលម្អិតជាក់លាក់អំពីប្រភេទព័ត៌មាន ដែលអាចនឹងមានប្រយោជន៏នៅក្នុងការពុះពារល់នឹងការប្រែប្រួលអាកាសធាតុឡើយ ។ទោះជាយ៉ាងណាក៏ដោយ កសិករភាគច្រើនបានពន្យល់អំពីព័ត៌មាន តាមទម្រង់ជាបច្ចេកទេសនិងជំនាញខាងកសិកម្ម ។ ទាក់ទងនឹងកខ្វះខាតការគាំទ្រខាងស្ថាប័ន កសិករចាប់អារម្មណ៍ថាភូមិរបស់ពួកគេមិនបានទទួលគាំទ្រសមស្របពី NGOs និងពីរដ្ឋាភិបាលឡើយ ។ គេគួរតែធ្វើការវិភាគជាបន្ថែមទៀតលើផ្នែកនេះ ដោយសារកសិករជាច្រើនបានបញ្ជាក់ថាមាន NGOs ដូចជា CWS និងស្ថាប័នរដ្ឋាភិបាលដែលធ្វើការនៅក្នុងភូមិគោលដៅ ដែលជួយក្នុងការដោះស្រាយបញ្ហាដែលទាក់ទងនឹងគ្រោះរាំងស្ងួតដូចមានចែងនៅក្នុងផ្នែកនៃការឆ្លើយតបជាវិជ្ជមានខាងក្រោម ។

ចម្លើយចំពោះសំណួរទី៣ មានភាពខុសគ្នាខ្លះៗបើគិតតាមភេទ ។ គ្រប់ក្រុមស្ត្រី (ស្ត្រីមកពីភូមិទាំងប្រាំ) បានចាប់អារម្មណ៍អំពីកង្វះធនធានទឹក និងឧបសគ្គដ៏ចម្បងក្នុងការបន្សាំដោយមានតែក្រុមបុរសចំនួនបីប៉ុណ្ណោះ ដែលមានចំណាប់អារម្មណ៍ដូចគ្នានេះ ។ គម្រោងនេះអាចព្យាយាមពិនិត្យមើលបន្ថែមទៀតអំពីមូលហេតុដែលក្រុមស្ត្រីទាំងអស់ផ្តល់ចម្លើយបែបនេះ ។ ដូចគ្នានេះដែរ ក្រុមស្ត្រីចំនួនបួនក្នុងចំណោមប្រាំក្រុមបានបង្ហាញថាមានការគាំទ្រខាងផ្នែកស្ថាប័នត្រឹមតិចតួចប៉ុណ្ណោះហើយពួកគាត់ខ្វះបច្ចេកទេសកសិកម្ម ។ កត្តាដែលអាចជាមូលហេតុប្រហែលជាកើតឡើងដោយសារតួលេខស្ថិតិដែលមានតែស្ត្រីមួយចំនួនតូចប៉ុណ្ណោះដែលបានទទួលសេវាកម្មផ្សព្វផ្សាយកសិកម្ម (ក្រសួងកសិកម្ម២០០៦[១]) ។ ស្ថាប័ននៅមូលដ្ឋានក៏អាចមានចំណូលចិត្តធ្វើការតែជាមួយបុរសផងដែរ ដូច្នេះស្ត្រីអាចមិនបានជួបធ្វើការជាមួយ NGOs ដែលប្រតិបត្តិការនៅទីនោះ ។

[១] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៦ : យុទ្ធសាស្ត្រនិងគោលនយោបាយបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ។

# តារាង ៤.៣: តារាងសង្ខេបពីចម្លើយដែលឆ្លើយញឹកញាប់សម្រាប់សំណួរទី៣

| ហេតុផលសម្រាប់ចម្លើយអវិជ្ជមាន | សំណួរទី៣ | ហេតុផលសម្រាប់ចម្លើយវិជ្ជមាន |
|---|---|---|
| ១. កង្វះធនធានទឹក (ទំនប់ អណ្តូង ប្រព័ន្ធស្រោចស្រព)។<br>២. កង្វះបច្ចេកទេសកសិកម្ម។<br>៣. កង្វះការគាំទ្រខាងស្ថាប័ន។<br>៤. កង្វះព័ត៌មាន។<br>៥. កង្វះប្រាក់។ | តើមានអ្វីខ្លះជាឧបសគ្គក្នុងការបន្សាំទៅនឹងកំណើនគ្រោះរាំងស្ងួត? តើអ្នកនិងសហគមន៍របស់អ្នក មានមធ្យោបាយអ្វីខ្លះដើម្បីគ្រប់គ្រងបញ្ហានានាដែលកើតមានកាន់តែញឹកញាប់?<br>ពិន្ទុ<br>៣.៦៤<br><br>តើធ្វើបែបណាដើម្បីអាចកែលម្អពិន្ទុនេះ?<br>១. ជីកស្រះបន្ថែមនិងសង់ប្រព័ន្ធស្រោចស្រព។<br>២. មានសត្វដែលធន់នឹងជម្ងឺ។<br>៣. មានពូជស្រូវ (ពូជស្រូវស្រាល)។ និងពូជដំណាំ សមស្របផ្សេងទៀត។<br>៤. មានការគាំទ្រខាងស្ថាប័នបន្ថែមទៀត។ | ១. មានការគាំទ្រពីរដ្ឋាភិបាល និង NGOs ផ្សេងទៀត។<br>២. មានក្រុមសន្សំប្រាក់ខ្លះៗ។<br>៣. មានព្រៃការពារ។ |

ទម្រង់ហាស់ ខាងលើបង្ហាញថាពិន្ទុVRA សម្រាប់សំណួរ៣គឺ ៣.៦៤។ ពិន្ទុនេះមានន័យថាកសិករយល់ថាខ្លួនឯងងាយរងគ្រោះនៅពេលគិតអំពីសមត្ថភាពរបស់ខ្លួន ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

សំណួរ៤: ចូរដាក់ពិន្ទុអំពីទំនុកចិត្តរបស់អ្នកថា (សកម្មភាពនៃគម្រោងនេះ) នឹងបន្តក្រោយពេលគម្រោងនេះចប់?

ទោះបីសំណួរ ៤ ត្រូវបានសួរនៅក្នុងលំហាត់ VRA ក៏ដោយ ទិន្នន័យដែលប្រមូលបានមិនត្រូវបានពិចារណាឡើយ ដោយសារតែចម្លើយមិនមានភាពច្បាស់លាស់។ កសិករមានការយល់ដឹងអំពីគោលគំនិតនៃការប្រែប្រួលអាកាសធាតុ ទោះជាយ៉ាងណាក៏ដោយពួកគេមិនបានដឹងពេញលេញអំពីសកម្មភាពគម្រោងនេះឡើយ ដូច្នេះវាជាការលំបាកសម្រាប់ពួកគេក្នុងការដាក់ពិន្ទុអំពីកម្រិតទំនុកចិត្តលើគម្រោងនេះ។ ផលលទ្ធផលសន្ទស្សន៍ VRA សម្រាប់ឃុំបុសលាវ និងទឹកក្រហម មិនរាប់បញ្ចូលពិន្ទុដែលបានផ្តល់សម្រាប់សំណួរទី៤ឡើយ។

### ៤.៣.១ មូលហេតុនៃចម្លើយវិជ្ជមាន

ទោះបីផ្តោតលើដំណើរការ VRA ក៏ដោយ នៅក្នុងការធ្វើអត្តសញ្ញាណថាតើការប្រែប្រួលអាកាសធាតុ មានឥទ្ធិពលអវិជ្ជមានបែបណាមកលើសហគមន៍ នៅក្នុងករណីខ្លះការប្រែប្រួលអាកាសធាតុអាចនាំមកនូវលទ្ធផលវិជ្ជមានផងដែរ ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងករណីខេត្តព្រះវិហារ កសិករមិនអាចធ្វើអត្តសញ្ញាណវិស័យដែលទទួលឥទ្ធិពលវិជ្ជមានពីការប្រែប្រួលអាកាសធាតុឡើយ ។ ទោះជាយ៉ាងនេះក៏ដោយ កសិករបានចង្អុលទៅវិស័យនានាដូចតទៅថា ជាការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ។ (សូមមើលរូបខាងក្រោម)

## រូប ៤.៤: កត្តាកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ




រូបនេះបង្ហាញពីការសង្ខេបចម្លើយវិជ្ជមានក្នុងសំណួរ ទី១ ទី២ និងទី៣ ដែលក្រុមនានាបានកត់សម្គាល់ជាញឹកញាប់ និងយ៉ាងហោចណាស់នៅក្នុងភូមិចំនួនបី នៃភូមិទាំង៥ ។

១. ការគាំទ្រពី NGO

២. ការគាំទ្រពីរដ្ឋាភិបាល

៣. ការផ្តល់សេវាកម្មសុខភាពសត្វ

៤. វត្ថុមានអណ្តូងសកម្មភាពគម្រោង RULIP

បើទោះជាកសិករមើលឃើញពីកង្វះការគាំទ្រខាងស្ថាប័នថាជាឧបសគ្គក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុក៏ដោយ ការគាំទ្រពី NGO ត្រូវបានកត់សម្គាល់នៅក្នុងភូមិទាំងប្រាំ ។ អង្គការសេវាកម្ម និចពិភពលោក (CWS) មានភាពលេចធ្លោនៅក្នុងភូមិទាំងប្រាំ ដែលបានចូលរួមនៅក្នុងដំណើរការ VRA និងបានចូលរួមនៅក្នុងការបណ្តុះបណ្តាលអំពីការបង្កើតសួនបន្លែ ការផ្តល់អាហារ

សម្រាប់កុមារអាយុក្រោម២ឆ្នាំ សេវាកម្មសុខភាពទឹកនិងអនាម័យ (ដែលរួមទាំង អណ្តូង បង្គន់ និងធុងចម្រោះទឹក)។ អង្គការកាកបាទក្រហមកម្ពុជា (CRC) និងវិទ្យាស្ថានខ្មែរដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ (KIPD) ក៏ត្រូវបានកត់សម្គាល់ផងដែរ ប៉ុន្តែមិនទំនងជា លេចធ្លោនៅក្នុងភូមិទាំងប្រាំនេះឡើយ ហើយមិនមានការបញ្ជាក់ច្បាស់ទេថា តើសកម្មភាពអ្វីខ្លះដែលពាក់ព័ន្ធជាមួយ NGOs ទាំង នេះ។

ការគាំទ្ររបស់រដ្ឋាភិបាលក៏ត្រូវបានកត់សម្គាល់ផងដែរនៅក្នុងភូមិភាគច្រើន។ ការគាំទ្រនេះរាប់បញ្ចូលការផ្តល់ពូជ និងការបណ្តុះបណ្តាលដោយមន្ទីរកសិកម្មខេត្ត អំពីបច្ចេកទេសកសិកម្ម បើទោះជាការគាំទ្រនេះទំនងជាតាមរយៈគម្រោងនានាដូចជាគម្រោង RULIP ដែលទទួលមូលនិធិពី IFAD ក៏ដោយ។ មន្ទីរធនធានទឹកនិងឧតុនិយម និងមន្ទីរអភិវឌ្ឍន៍ជនបទក៏ត្រូវបានកត់សម្គាល់ផងដែរ ដោយគ្មានការបញ្ជាក់លម្អិតអំពីប្រភេទនៃការគាំទ្រឡើយ។ ការគាំទ្រលើការថែទាំសុខភាពសត្វ ក៏ត្រូវបានគូសបញ្ជាក់ផងដែរយ៉ាងហោចណាស់នៅក្នុងភូមិចំនួនបី ដែលពួកគេបានបញ្ជាក់ថាពួកគេបានទទួលការបណ្តុះបណ្តាលអំពីការចិញ្ចឹមសត្វនិងការធ្វើសួនបន្លែ។ ពួគេបានទទួលសត្វ (កូនជ្រូកនិងមាន់) ឈើហូបផ្លែ ការចាក់ថ្នាំបង្ការ ។ល។ ដូចគ្នានេះដែរសកម្មភាពទាំងនេះខ្លះៗទាក់ទងជាមួយអន្តរាគមន៍កំពុងអនុវត្តនៅក្នុងគម្រោង RULIP។ ការកត់សម្គាល់ជាក់លាក់អំពីសកម្មភាពគម្រោង RULIP បានធ្វើឡើងដោយយោងទៅការផ្តល់គ្រាប់ពូជ ការចិញ្ចឹមសត្វ ការធ្វើសួនបន្លែ និងការបណ្តុះបណ្តាលអំពីបច្ចេកទេសកសិកម្ម។ វត្តមានអណ្តូង ទំនប់ និងវត្តមានដីសម្រាប់សាងសង់ទំនប់ ស្រះសហគមន៍ត្រូវបានមើលឃើញថាជាផ្នែកដែលអាចជួយទប់ទល់នឹងផលប៉ះពាល់អវិជ្ជមានពីការប្រែប្រួលអាកាសធាតុ។

## ៤.៤ ពិន្ទុនៅក្នុង VRA

ផ្អែកលើលទ្ធផលពីខាងលើសន្ទស្សន៍ជារួមនៅក្នុង VRA សម្រាប់ឃុំទឹកក្រហមគឺ ៤.0៤ ដែលបង្ហាញថា កសិករគិតថាខ្លួនឯងងាយរងគ្រោះជាខ្លាំងពីការប្រែប្រួលអាកាសធាតុ ជាពិសេសដោយសារគ្រោះរាំងស្ងួតដែលអាចកើតឡើងកាន់តែញឹកញាប់ជាងមុនក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ជាទូទៅភូមិនានាមានកម្រិត នៃភាពងាយរងគ្រោះប្រហាក់ប្រហែលគ្នា បើទោះជាភូមិចាត់តាំង ទំនងជាងាយរងគ្រោះជាងគេនៅក្នុងឃុំគោលដៅនេះក៏ដោយ ចំណែកភូមិទឹកក្រហមទំនងជាមិនសូវងាយរងគ្រោះឡើយធៀបនឹងភូមិដទៃទៀតនៅក្នុងឃុំទឹកក្រហម។ លទ្ធផលក៏បង្ហាញផងដែរថា អ្នកភូមិគិតថាពួកគាត់នឹងកាន់តែងាយរងគ្រោះប្រសិនបើមានកំណើនទឹកជំនន់ នៅក្នុងភូមិគោលដៅទាំងនេះ ដូចដែលបានឃើញតាមរយៈពិន្ទុខ្ពស់សម្រាប់សំណួរ២ ។

### ៤.៤.១ ការកែលម្អពិន្ទុ VRA

សម្រាប់សំណួរទាំងបី កសិករត្រូវបានសួរអំពីវិធីដើម្បីកែលម្អពិន្ទុសម្រាប់សំណួរនីមួយៗ។ ដោយសារចម្លើយមានលក្ខណៈប្រហែលគ្នា ការឆ្លើយតបអំពីរបៀបកែលម្អពិន្ទុត្រូវបានដាក់បញ្ចូលគ្នា ហើយចម្លើយដែលមានញឹកញាប់ជាងគេត្រូវបានដាក់បញ្ចូលក្នុងរូបខាងក្រោមនេះ។ ការជ្រើសរើសចម្លើយខាងក្រោមនេះ ក៏បានធ្វើឡើងដោយផ្អែកលើភាពញឹកញាប់នៃចម្លើយ ដែលបានពីយ៉ាងហោចណាស់ភូមិចំនួនបី ក្នុងចំណោមភូមិទាំងប្រាំផងដែរ។

## រូប ៤.៥: វិធីកែលម្អពិន្ទុ VRA




តាមលំដាប់នៃសារៈសំខាន់ កសិករនៅទឹកក្រហម មានអារម្មណ៍ថា ពិន្ទុសម្រាប់ VRA អាចកែលម្អបាន ដោយផ្តោតលើផ្នែកនានាដូចតទៅ :

១. ការស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រព ទំនប់ និងប្រឡាយ

២. ការផ្តល់លទ្ធភាពក្នុងការប្រើប្រាស់ពូជស្រូវកែលម្អខុសៗគ្នា អណ្តូងសហគមន៍ និងស្រះសហគមន៍

៣. ការបណ្តុះបណ្តាលអំពីបច្ចេកទេសថ្មីៗខាងកសិកម្ម

៤. ការផ្តល់សេវាកម្មសុខភាពសត្វ

៥. ការផ្តល់បច្ចេកទេសគ្រប់គ្រងសត្វចិញ្ចឹម

ការផ្តោតលើធនធានទឹក ក្នុងនាមជាវិធីចម្បងនៃការកែលម្អពិន្ទុ VRA ឆ្លុះបញ្ចាំងអំពីឧបសគ្គចម្បងៗចំពោះការបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ (សូមមើលតារាងខាងក្រោម) និងចំណាប់អារម្មណ៍ជាទូទៅផងដែរថា ការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់អវិជ្ជមានមកលើធនធានទឹក ដូចមានគូសបញ្ជាក់នៅក្នុងសំណួរ ១ និង២ ។ នៅក្នុងរូបខាងលើ ទាំងក្រុមស្ត្រីនិងបុរសមកពីភូមិទាំងអស់ បានបង្ហាញថាភាពងាយរងគ្រោះនៅក្នុងភូមិរបស់ពួកគេអាចកាត់បន្ថយបាន ប្រសិនបើប្រព័ន្ធស្រោចស្រពត្រូវបានសាងសង់ ឬស្តារឡើងវិញ អាស្រ័យលើថាតើភូមិនោះមានប្រព័ន្ធស្រោចស្រពហើយឬនៅ។

ពូជស្រូវកែលម្អនិងការសង់អណ្តូងដែលមានទឹកពេញមួយឆ្នាំ និងស្រះសហគមន៍ ត្រូវបានចាត់ទុកថាមានសារៈសំខាន់ដូចគ្នា។ ទាក់ទងនឹងពូជស្រូវកសិករ បានបង្ហាញថាភាពងាយរងគ្រោះខាងកសិកម្មអាចកាត់បន្ថយបាន ប្រសិនបើពួកគាត់មានលទ្ធភាពទទួលបានពូជស្រូវដែលធន់នឹងគ្រោះរាំងស្ងួតជាពូជស្រូវស្រាលនិងដែលផ្តល់ទិន្នផលខ្ពស់។ បច្ចេកទេសកសិកម្មលើដំណាំស្រូវ ក៏ត្រូវបានចាត់ទុកថាមានសារៈសំខាន់ផងដែរនៅក្នុងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។ នៅទីនេះបច្ចេកទេសក៏សំដៅ

លើការពង្រីកមុខដំណាំកសិកម្មផងដែរ ដែលរួមទាំងពូជបន្លែ ដំឡូង សណ្តែក ជាច្រើនមុខនិងការគ្រប់គ្រងសត្វចិញ្ចឹម ទោះបីកសិករមិនបានកត់សម្គាល់ជាក់លាក់អំពីប្រភេទសត្វ និងវារីវប្បកម្មក៏ដោយ ។

តារាងខាងក្រោមបង្ហាញនូវការប្រៀបធៀបអំពីឧបសគ្គក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងវិធីដើម្បីកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ។

តារាង៤.៤: ការប្រៀបធៀបអំពីឧបសគ្គក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកសសធាតុ និងវិធីកែលម្អពិន្ទុ VRA

| ឧបសគ្គ | ការកែលម្អពិន្ទុ |
|---|---|
| ១. កង្វះលទ្ធភាពក្នុងការទទួលបានធនធានទឹក ។ | ១. សង់ប្រព័ន្ធស្រោចស្រព ។ |
| ២. ខ្វះប្រាក់ ។ | ២. ផ្តល់ពូជស្រូវកែលម្អ អណ្តូង និងស្រះសហគមន៍ ។ |
| ៣. ខ្វះការគាំទ្រពី NGOs ខ្វះព័ត៌មាន និងខ្វះបច្ចេកទេសកសិកម្ម ។ | ៣. បច្ចេកទេសកសិកម្ម ។ |
| | ៤. សេវាកម្មសុខភាពសត្វ ការគ្រប់គ្រងសត្វចិញ្ចឹម ។ |

ជាការគួរឱ្យភ្ញាក់ផ្អើល សេវាកម្មសុខភាពសត្វនិងការគ្រប់គ្រងសត្វចិញ្ចឹម ដែលជាវិធីមួយសម្រាប់កែលម្អពិន្ទុ VRA ត្រូវបានកត់សម្គាល់ដោយអ្នកភូមិត្រឹមមួយចំនួនតូចប៉ុណ្ណោះ បើទោះជាកសិករមើលឃើញថា ការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់អវិជ្ជមានខ្លាំងក្លាមកលើសត្វចិញ្ចឹមក៏ដោយ (សូមមើលរូបទី៤.១ និង ៤.២ ខាងលើ) ។ កង្វះការគាំទ្រខាងស្ថាប័ន និង-កង្វះប្រាក់ ដែលបានកត់សម្គាល់ថាជាឧបសគ្គក្នុងការបន្សាំ មិនត្រូវបានលើកឡើងថាជាអាទិភាពខ្ពស់ឡើយនៅទីនេះដោយសារកសិករទំនងជាមានចំណាប់អារម្មណ៍ខ្លាំងបំផុតតែលើសេវាដែលផ្តល់ដោយ NGOs ជាងត្រឹមតែវត្តមាន NGOs ។ ដូចគ្នានេះដែរកសិករអាចចាប់ណាប់អារម្មណ៍លើសេវាកម្មនានា ដែលពួកគេអាចចំណាយប្រាក់ដើម្បីទិញជាងត្រឹមតែមានប្រាក់ ។

## ៤.៥ ការវិភាគទិន្នន័យដែលប្រមូលបាន

### ការវិភាគភាពងាយរងគ្រោះ និងវិស័យនានាដែលគម្រោងអាចជួយអន្តរាគមន៍

ផ្អែកលើភាពញឹកញាប់នៃចម្លើយដែលផ្តល់ដោយក្រុមអ្នកភូមិខុសៗគ្នានៅពេលសម្ភាស ភាពងាយរងគ្រោះសំខាន់ៗពីការប្រែប្រួលអាកាសធាតុ ត្រូវបានធ្វើអត្តសញ្ញាណដូចខាងក្រោមនេះ :

# ១. ផលប៉ះពាល់មកលើធនធានទឹក

## ១.១ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើធនធានទឹក

**១.១.១ ទឹកសម្រាប់កសិកម្ម :** ក្នុងគ្រោះរាំងស្ងួតមានឥទ្ធិពលមកលើធនធានទឹក ដោយធ្វើឱ្យបាត់បង់ធនធានទឹកដែលសត្វប្រើប្រាស់ និងកំហិតលើសមត្ថភាពរបស់ពួកគេក្នុងការដាំបន្លែនៅរដូវប្រាំង និងក៏រារាំងដល់ការស្រោចស្រពផងដែរនៅពេលមានកូនរដូវប្រាំង ។ ផ្ទុយទៅវិញទឹកជំនន់បានបំផ្លាញទំនប់ និងប្រព័ន្ធស្រោចស្រពក៏ដូចជាឥទ្ធិពលប្រហែលគ្នានឹងគ្រោះរាំងស្ងួតផងដែរ ។

**១.១.២ ទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ :** ក្នុងអណ្តូងរីងស្ងួតនៅក្នុងឆ្នាំរាំងស្ងួត ។ ទឹកពីស្រះនានាប្រចាំគ្រួសារ បានថយចុះទាំងបរិមាណ និងគុណភាពនៅក្នុងរដូវប្រាំង ដែលនាំឱ្យមានបញ្ហាសុខភាព ដូចជារោគរាគរូស ។

## ១.២ ដំណោះស្រាយរបស់កសិករ

**១.២.១** ការកសាង និងស្តារប្រព័ន្ធធានាសាស្ត្រសម្រាប់ការស្រោចស្រព ទឹកសម្រាប់សត្វ និងសម្រាប់ដាំបន្លែនៅក្នុងរដូវប្រាំង ត្រូវបានកសិករទាំងអស់កត់សម្គាល់ ។

**១.២.២** ម៉ាស៊ីនបូមទឹកសហគមន៍ ក៏ត្រូវបានកសិករខ្លះកត់សម្គាល់ផងដែរថាជាវិធីល្អមួយសម្រាប់កាត់បន្ថយផលប៉ះពាល់នៃគ្រោះរាំងស្ងួតនៅក្នុងតំបន់នេះ ។

**១.២.៣** កសិករសង្កេតឃើញថា ពួកគេមិនអាចបន្សុំនឹងការប្រែប្រួលអាកាសធាតុបានដោយសារពួកគេខ្វះនូវអណ្តូងដែលអាចផ្គត់ផ្គង់ទឹកបានពេញមួយឆ្នាំ ។ ដូច្នេះពួកគេគិតថាការជីកអណ្តូងនិងស្រះ សម្រាប់ផ្តល់ទឹកប្រើប្រាស់ក្នុងគ្រួសារ គឺជាដំណោះស្រាយមួយដ៏សមស្រប ។

## ១.៣ អន្តរាគមន៍របស់គម្រោង

ទោះបីគម្រោងនេះមិនមែនជាគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងមិនអាចសាងសង់ទំនប់និងផ្លូវថ្នល់ក៏ដោយគម្រោងនេះនឹងអនុវត្តបង្ហាញពីរបៀបកសាងប្រព័ន្ធស្រោចស្រពដែលធន់ទ្រាំនឹងអាកាសធាតុ ដែលអាចទប់ទល់នឹងផលប៉ះពាល់ពីកំណើនគ្រោះថ្នាក់នៃអាកាសធាតុដូចជាខ្យល់ព្យុះនិងទឹកជំនន់ ។ ក្នុងន័យនេះប្រព័ន្ធអូរក្សាន្ត ត្រូវបានធ្វើអត្តសញ្ញាណនៅឃុំទឹកក្រហមសម្រាប់ការអនុវត្តបង្ហាញវិធីនេះ ។

កសិករត្រូវការម៉ាស៊ីនដើម្បីបូមទឹក ប៉ុន្តែវានឹងមិនមាននិរន្តរភាពទេសម្រាប់គម្រោងក្នុងការផ្តល់ម៉ាស៊ីនបូមទឹក ។ ជាជំនួសគម្រោងនេះនឹងពិនិត្យមើលបច្ចេកវិទ្យាសមស្រប ដែលអាចផ្តល់សេវាកម្មដូចគ្នានេះតាមថ្លៃដែលអាចជាវបាន ។ មន្ត្រីគម្រោងបានពិភាក្សាជាមួយអង្គការក្នុងស្រុកមួយចំនួន ដើម្បីពិនិត្យលទ្ធភាពសង់ប្រព័ន្ធបូមទឹកដើរដោយថាមពលខ្យល់ និងអាចជាប្រព័ន្ធបូមទឹកដើរដោយថាមពលព្រះអាទិត្យផងដែរ ។

ទាក់ទងនឹងអណ្តូង គម្រោងនេះនឹងពិគ្រោះយោបល់ជាមួយមន្ទីរអភិវឌ្ឍន៍ជនបទ អំពីវិធីល្អបំផុតដែលមន្ទីរនេះអាច

ផ្តល់ទឹកស្អាតប្រកបដោយនិរន្តរភាព ។គម្រោងនេះអាចខ្វះអណ្តូងថ្មី ឬអាចរិះរកមធ្យោបាយក្នុងការនាំយកទឹកស្អាតពីភ្នំតាមការលើកស្នើដោយអ្នកភូមិខ្លះ ។ ទោះជាបែបនេះក៏ដោយ គម្រោងនេះនឹងមិនចូលរួមនៅក្នុងការសាងសង់ស្រះប្រចាំគ្រួសារឡើយ ដោយសារសកម្មភាពទាំងនេះអាចផ្តល់ផលសម្រាប់តែគ្រួសារនីមួយៗប៉ុណ្ណោះជាជាងសម្រាប់សហគមន៏ទាំងមូល លើកលែងតែក្នុងករណីដែលគម្រោងនេះត្រូវអនុវត្តបង្ហាញពីបច្ចេកវិទ្យាសមស្រប ។

## ២. ផលប៉ះពាល់មកលើផលិតភាពកសិកម្ម

### ២.១ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើកសិកម្ម

**២.១.១** កសិករភាគច្រើនចាត់ទុកគ្រោះរាំងស្ងួតថាបង្កឱ្យមានការខូចខាតជាច្រើនដល់ផលិតផលកសិកម្ម ។ ការខូចខាតនេះ រាប់បញ្ចូលការរលួយសំណាបនៅក្នុងរដូវសាបមុននឹងអាចដកទៅស្ទូង ។ គ្រោះរាំងស្ងួតនិងការបាត់បង់ទឹក នាំឱ្យមានស្រូវពុំដាក់គ្រាប់និងជាលទ្ធផលគឺបានទិន្នផលទាប ។ កសិករខ្លះក៏បានកត់សម្គាល់ផងដែរអំពីកំណើនការបំផ្លាញដំណាំដោយសារសត្វចង្រៃ ដែលជាប្រការទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ។

**២.១.២** គ្រោះរាំងស្ងួតក៏បង្កការប៉ះពាល់មកលើដំណាំផ្សេងទៀតផងដែរ ភាគច្រើនពួកគេមិនអាចដាំដំណាំទាំងនោះបានទេនៅពេលដែលខ្វះទឹក ។

**២.១.៣** កង្វះពូជក៏ត្រូវបានកត់សម្គាល់ថាជាបញ្ហាមួយផងដែរនៅពេលដែលសំណាបត្រូវរលួយអស់ ពួកគេពុំមានពូជថ្មីសម្រាប់ស្ទូងឡើងវិញឡើយ ។

### ២.២ ដំណោះស្រាយរបស់កសិករ

**២.២.១ ពិពិធកម្មដំណាំ :** ការបង្កើនមុខដំណាំដែលកាត់បន្ថយហានិភ័យនៃការពឹងផ្អែកតែលើដំណាំស្រូវ ។ កសិករបានកត់សម្គាល់អំពីដំណាំដូចជា ដំឡូង និងបន្លែ ។ ពួកគាត់ក៏បានពោលផងដែរថា ការចិញ្ចឹមសត្វនិងត្រី គឺជាឧទាហរណ៏ផ្សេងទៀតអំពីការធ្វើពិពិធកម្មកសិកម្ម ។

**២.២.២ ពង្រឹកលទ្ធភាពធ្វើកសិកម្ម :** បន្ថែមលើការបង្កើនមុខដំណាំ កសិករក៏ចាប់អារម្មណ៏ផងដែរថាភាពងាយរងគ្រោះរបស់ពួកគាត់ អាចកាត់បន្ថយបានប្រសិនបើពួកគាត់បានទទួលជំនាញប្រសើរជាងមុន សម្រាប់ដាំស្រូវនិងដាំដំណាំផ្សេងទៀត និងចិញ្ចឹមសត្វ ។

**២.២.៣ កែលម្អពូជស្រូវ :** កសិករក៏ចាប់អារម្មណ៏ផងដែរថា ពូជស្រូវដែលបានកែលម្អ អាចកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគាត់ផងដែរ ។ នៅទីនេះ ការកែលម្អដែលបានលើកឡើង សម្តៅលើពូជដែលផ្តល់ទិន្នផលខ្ពស់ជាពូជស្រូវស្រាលនិងដែលធន់នឹងគ្រោះរាំងស្ងួត ។

### ២.៣ អន្តរាគមន៍របស់គម្រោង

យោបល់ខ្លះៗអំពីរបៀបកែលម្អពិន្ទុ មានបញ្ចូលទៅក្នុងសកម្មភាពដែលបានគ្រោងទុកសម្រាប់គម្រោងនេះរួចទៅហើយ ។ គម្រោងនេះបានចាប់ផ្ដើមធ្វើការពិនិត្យមើលពូជស្រូវដែលធន់នឹងភាពរាំងស្ងួតនិងទឹកជំនន់ ។ ទោះជាយ៉ាងណាក៏ដោយគម្រោងនេះអាចឈានមួយជំហានបន្ថែមទៀត ដោយរួមបញ្ចូលការបង្កើនពូជនិងការជ្រើសរើសពូជ ដើម្បីឱ្យពូជដែលបានកែលម្អនោះបានដល់ដៃកសិករកាន់តែច្រើនឡើងដោយតម្លៃទាបជាងមុន ។ ការធ្វើបែបនេះនឹងអាចធ្វើឱ្យកសិករងាយទទួលបានពូជល្អជាងមុននិងបង្កើនភាពធន់នៃពូជស្រូវរបស់ខ្លួនទៅនឹងគ្រោះរាំងស្ងួតនៅក្នុងករណីយ៉ាំទឹកក្រហម ។ កសិកររាយការណ៍ថា ពួកគាត់ត្រូវទិញពូជថ្មីជារៀងរាល់បីទៅបួនឆ្នាំម្ដងដោយសារពូជដែលគាត់ទទួលបានបាត់បង់ភាពសុទ្ធនិងទិន្នផលធ្លាក់ចុះ ។ ហេតុផលដែលនាំឱ្យមានការថយចុះនេះ គឺការលាយពូជស្រូវខុសៗគ្នាពីស្រែដែលនៅជាប់គ្នា ។ ការសង្កេតដែលបានធ្វើឡើងជាមួយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) អំពីពូជស្រូវបង្ហាញថាកសិករមានឆន្ទៈខ្ពស់ក្នុងការប្រើប្រាស់ពូជស្រូវកែលម្អ ។ គម្រោងនេះក៏អាចស្វែងរកសំណុំលក្ខណៈដែលធ្វើឱ្យស្រូវឆាប់ផ្ដល់ផលផងដែរ ជាការបន្ថែមលើពូជស្រូវដែលធន់នឹងគ្រោះរាំងស្ងួតនិងទឹកជំនន់ ។

លើសពីនេះ គម្រោងនេះគ្រោងធ្វើការសិក្សាវាយតម្លៃមួយអំពីការធ្វើដំណាំស្រូវដែលសមស្របបំផុតសម្រាប់តំបន់ងាយជួបប្រទះគ្រោះរាំងស្ងួត ។ ដោយផ្អែកលើរបកគំហើញនេះ គម្រោងនេះនឹងអនុវត្តសាកល្បងវិធីសាស្ត្រទាំងនេះនិងជម្រុញវិធីនានាដែលកសិករលើកស្នើឡើង ។ លើសពីនេះនៅពេលដែលគម្រោង កំពុងអនុវត្តក្រោមភាពជាដៃគូជាមួយកម្មវិធី កែលម្អជីវភាពរស់នៅតាមជនបទនៃ IFAD/UNDP សេវាកម្ម ផ្សព្វផ្សាយអំពីទម្លាប់ល្អសម្រាប់ធ្វើស្រែ និងដំណាំផ្សេងទៀតនិងបន្លែ ក៏អាចធ្វើបានផងដែរ តាមរយៈជំនួយពីកម្មវិធី RULIP ដែលបានចូលរួមរួចមកហើយនៅក្នុងសកម្មភាពខ្លះៗទាំងនេះ ។

## ៣. ផលប៉ះពាល់មកលើសុខភាពសត្វនិងមនុស្ស

### ៣.១ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសុខភាព

**៣.១.១ សត្វ** : កសិករភាគច្រើនបំផុតមានចំណាប់អារម្មណ៍ថា ការប្រែប្រួលអាកាសធាតុ (គ្រោះរាំងស្ងួត) ធ្វើឱ្យសត្វឈឺ ។ ទោះបីមានការសិក្សាជាច្រើនអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើកសិកម្មនិងសុខភាពមនុស្សក៏ដោយ មានការសិក្សាត្រឹមបន្តិចបន្តួចប៉ុណ្ណោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសត្វចិញ្ចឹម ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងតំបន់គោលដៅ ផលប៉ះពាល់អវិជ្ជមាននៃគ្រោះរាំងស្ងួតបានបង្ហាញជាអាទិភាពខ្ពស់នៅក្នុងចម្លើយទាំងពីស្ត្រី និងបុរស ។ ជម្ងឺនានាដែលកសិករបានលើកឡើងរួមមាន ជម្ងឺញូកាស់ (newcastle) នៅលើសត្វមាន់ អ៊ុតក្ដាម និងរោគសារទឹកនៅលើសត្វគោនិងក្របី ។

**៣.១.២ មនុស្ស :** ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលមកលើសុខភាពមនុស្ស ក្រោមទម្រង់ជារោគរាគរូស ឈឺពោះ ។ល។ កសិករបានបញ្ជាក់ថាបញ្ហាសុខភាពមនុស្សកាន់តែធ្ងន់ធ្ងរ ដោយសារតែកង្វះខាតមណ្ឌលសុខភាព និងថ្នាំពេទ្យ ។

## ៣.២ ដំណោះស្រាយរបស់កសិករ

**៣.២.១ មណ្ឌលសុខភាព :** កសិករចាប់អារម្មណ៍ថា សុខភាពរបស់ពួកគាត់អាចកែលម្អបាន ប្រសិនបើមានការសាងសង់មណ្ឌលសុខភាពនៅក្នុងកន្លែងរបស់ពួកគាត់ ។

**៣.២.២ អនាម័យ :** ទោះជាយ៉ាងណាក៏ដោយ កសិករខ្លះអាចមើលឃើញមូលហេតុដើមនៃភាពទន់ខ្សោយនៃសុខភាពមនុស្សដោយសារតែការប្រែប្រួលអាកាសធាតុ និងបានស្នើសុំឱ្យមានធុងចម្រោះទឹកដើម្បីសម្អាតទឹករបស់ពួកគេ អណ្តូងទឹកស្អាត បង្គន់អនាម័យ និងការផ្សព្វផ្សាយអំពីការថែរក្សាសុខភាព ។

**៣.២.៣ សត្វដែលធន់នឹងជម្ងឺ :** ទាក់ទងនឹងសុខភាពសត្វ កសិករបានស្នើសុំឱ្យមានសត្វដែលធន់នឹងជម្ងឺ ។ មាន់និងជ្រូក ជាពពួកសត្វភាគច្រើនដែលបានចិញ្ចឹមនៅក្នុងសហគមន៍គោលដៅ បើទោះជាមានគោនិងក្របីខ្លះៗដែរ ក៏ដោយ ។

**៣.២.៤ ការគ្រប់គ្រងសត្វចិញ្ចឹម :** លើសពីនេះ កសិករក៏បានស្នើសុំឱ្យមានបុគ្គលិកសុខភាពសត្វប្រចាំភូមិ និងកម្មវិធីផ្តល់ថ្នាំបង្ការថែមទៀតផងដែរ ។

## ៣.៣ អន្តរាគមន៍របស់គម្រោង

គម្រោងពុំមានមូលនិធិគ្រប់គ្រាន់សម្រាប់សង់មណ្ឌលសុខភាព ឬផ្តល់ជំនាញបច្ចេកទេសសេវាសុខភាព ឡើយ ដូច្នេះគម្រោងនេះមិនអាចឆ្លើយតបនឹងសំណើនេះបានឡើយ ។ ទោះជាយ៉ាងណាក៏ដោយ គម្រោងនេះអាចពិនិត្យមើលលទ្ធភាពក្នុងការផ្តល់ធុងចម្រោះទឹកនិងទឹកស្អាត ដូចបានពិភាក្សាខាងលើនៅក្នុងផ្នែកស្តីពីទឹក ។ ទោះជាយ៉ាងណាក៏ដោយ ជាជាងផ្តល់ធុងចម្រោះដោយឥតគិតថ្លៃ គម្រោងនេះអាចផ្សារភ្ជាប់ការចែកចាយធុងចម្រោះជាមួយក្រុមសន្សំប្រាក់ ។ ដូច្នេះសាច់ប្រាក់ដែលបានពីការលក់ធុងចម្រោះ រួមចំណែកទៅក្នុងមូលនិធិសន្សំ ។ គម្រោងនេះនឹងពិភាក្សាបន្ថែមទៀតជាមួយដៃគូ គម្រោងនៅថ្នាក់ខេត្ត ថាតើគម្រោងនេះគួរតែចូលរួមនៅក្នុងការអប់រំសុខភាពដែរឬទេ ដោយសារដៃគូសហការមិនមាន ជំនាញលើផ្នែកសុខភាពសាធារណៈ ។ ជម្រើសមួយផ្សេងទៀតអាចជាការផ្សារភ្ជាប់កសិករជាមួយ NGOs ដែលចូលរួមនៅក្នុងជំនាញនេះ ។ កសិករបាននិយាយថាមានអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានផ្តល់នូវសេវាកម្មផ្នែកសុខភាពនិងអនាម័យដូចជា ថ្នាំពេទ្យ បង្គន់ ធុងចម្រោះ ការអប់រំសុខភាព រួមទាំងបានផ្តល់សេវាកម្មកសិកម្មផងដែរ ដូចជាផ្តល់ពូជបន្លែ វគ្គបណ្តុះបណ្តាលពីការគ្រប់គ្រងសត្វចញ្ចឹមជាដើម ។

ទាក់ទងនឹងសុខភាពសត្វ គម្រោងនេះនឹងសហការជាមួយ RULIP អំពីវិធីដើម្បីកែលម្អសេវាកម្មលើសុខភាពសត្វ ។ RULIP ចូលរួមនៅក្នុងកម្មវិធីចិញ្ចឹមជីវិតនៅជនបទ ដែលរួមបញ្ចូលការគ្រប់គ្រងសត្វចិញ្ចឹម (ចិញ្ចឹមមាន់ និងជ្រូក) សកម្មភាពទាំងនេះអាចពង្រីកទៅក្នុងតំបន់នានាក្រោមគម្រោងបន្តពី NAPA ។

## ៩. ការគ្រប់គ្រងធនធានធម្មជាតិ

បើទោះបីជាឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុមកលើធនធានធម្មជាតិដូចជាព្រៃឈើ មិនត្រូវបានគេលើកឡើងមកពិភាក្សាក៏ដោយ ក៏កសិករបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃព្រៃឈើក្នុងការឆ្លើយតបនឹងឥទ្ធិពលការប្រែប្រួលអាកាសធាតុដែរ ។

### ៩.១ ដំណោះស្រាយរបស់កសិករ

**៩.១.១** ព្រៃការពារត្រូវបានកសិករពីភូមិទឹកក្រហម និងភូមិចាត់តាំង កត់សម្គាល់ថាជាវិធីមួយដែលកសិករអាចទប់ទល់នឹងផលប៉ះពាល់ពីគ្រោះរាំងស្ងួតមកលើផលិតកម្មដំណាំ ។ នៅពេលដែលខ្វះស្បៀងអាហារ កសិករចូលទៅក្នុងព្រៃដើម្បីស្វែងរកផ្តៅ ត្រពាំង ផ្លែឈើ សម្រាប់ជាអាហារនិងដើម្បីលក់ ។

**៩.១.២** កសិករមានអារម្មណ៍ថា ភាពងាយរងគ្រោះរបស់ពួកគេអាចកាត់បន្ថយបាន ប្រសិនបើពួកគេដាំដើមឈើឡើងវិញ និងគ្រប់គ្រងព្រៃឈើបានប្រសើរជាងមុន ។

### ៩.២ អន្តរាគមន៍របស់គម្រោង

ព្រៃឈើអាចផ្តល់ផលិតផលនិងសេវាកម្មជាច្រើនដែលអាចជួយសហគមន៍ដែលរស់នៅក្នុងនិងជុំវិញព្រៃឈើដើម្បីទប់ទល់នឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ។ ពួកគេអាចបំពេញបន្ថែមលើរបរចិញ្ចឹមជីវិតរបស់ខ្លួនពីកសិកម្ម តាមរយៈផលិតផលពីព្រៃឈើសម្រាប់ជាអាហារនិងប្រាក់ចំណូល ឬកាន់តែមានសារៈសំខាន់នៅពេលដែលរបរចិញ្ចឹមជីវិតបឋម (កសិកម្ម) របស់ពួកគេមិនផ្តល់ផល ។ លើពីនេះព្រៃឈើមានតួនាទីដ៏សំខាន់នៅក្នុងការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដូចជានិយ័តកម្មវដ្តទឹកនិងទឹកជម្រាល និងកិច្ចការពារដី ដែលមានឥទ្ធិពលដោយផ្ទាល់មកលើកសិកម្ម ប្រសិនបើប្រព័ន្ធអេកូឡូស៊ីនានារងការរំខានឬខូចខាតដោយសារតែការប្រែប្រួលអាកាសធាតុ ។ ការថយចុះនៃផលិតផលនិងសេវាពីព្រៃឈើ អាចមានឥទ្ធិពលអវិជ្ជមានមកលើសហគមន៍ និងបង្កើនភាពងាយរងគ្រោះរបស់ពួកគេដោយសារតែការប្រែប្រួលអាកាសធាតុ ។ ដូច្នេះសកម្មភាពនៃគម្រោងនេះត្រូវតែគិតបញ្ចូលអំពីសារៈសំខាន់ដែលព្រៃការពារមានផ្តល់ឱ្យ នៅក្នុងការទ្រទ្រង់របរចិញ្ចឹមជីវិតជំនួសនិងសេវាកម្មបរិស្ថាន ធៀបនឹងផលិតភាពកសិកម្ម ដោយធានាថាព្រៃឈើនានាត្រូវបានថែរក្សា និងការពារ ។

គម្រោងនេះអាចឆ្លើយតបទៅនឹងសំណើនេះ ដោយសហការជាមួយគម្រោងផ្សេងទៀតដែលទទួលមូលនិធិពី UNDP និងដែលកំពុងអនុវត្តនៅក្នុងឃុំដូចគ្នានេះ ។ តំបន់អភិរក្សតាមរយៈការគ្រប់គ្រងតំបន់ទេសភាព (CALM) ដែលអនុវត្តដោយអង្គការអភិរក្សសត្វព្រៃ (WCS) ក្នុងបំណងឆ្លើយតបទៅនឹងការគំរាមកំហែងមកលើជីវៈចម្រុះសំខាន់ៗនៅក្នុងតំបន់ ខ្ពង់រាបខាងជើងនិងផ្តោតលើគោលបំណងសំខាន់ៗចំនួនបី :

១. ពង្រឹងការគ្រប់គ្រងជីវៈចម្រុះដោយរដ្ឋាភិបាលនៅតាមទីតាំងសំខាន់ៗ

២. រួមបញ្ចូលការពិចារណាអំពីជីវៈចម្រុះទៅក្នុងការកសាងផែនការប្រើប្រាស់ដីនៅថ្នាក់ខេត្ត និង

៣. បង្កើតការលើកទឹកចិត្តសម្រាប់សហគមន៍នានា និងជំនួញក្នុងមូលដ្ឋាន ដើម្បីទ្រទ្រង់ដល់ការអភិរក្ស

ការពិភាក្សាបន្ថែមទៀតជាមួយក្រុមការងារគម្រោងនិងបុគ្គលិក គម្រោង CALM អាចបង្ហាញពីវិធីមួយ ដើម្បីសហការលើការគ្រប់គ្រងព្រៃឈើ ។

# ៥. ការរកឃើញនៅក្នុងឃុំបុសលាវ ខេត្តក្រចេះ



*ខេត្តក្រចេះត្រូវបានគេស្គាល់ថាធ្លាប់រងគ្រោះដោយសារទឹកជំនន់និងខ្យល់ព្យុះ ប៉ុន្តែខេត្តនេះក៏កំពុងជួបប្រទះនូវគ្រោះរាំងស្ងួតញឹកញាប់ជាងមុនផងដែរ ។*

## ៥.១ សាវតា

ឃុំបុសលាវជាឃុំមួយនៅជាប់តាមបណ្តោយទន្លេមេគង្គ ចម្ងាយ ១០គ.ម ពីក្រុងក្រចេះ ស្ថិតនៅក្នុងស្រុកចិត្របុរី មានព្រំប្រទល់ខាងជើងជាប់ព្រៃកទេ និងរកាកណ្តាល ខាងត្បូងទល់ឃុំកញ្ជរ មានផ្ទៃដីសរុបប្រមាណ ៧.៧២៨ ហ.ត ។ ឃុំបុសលាវ ចែកចេញជា៨ភូមិគឺ ភូមិបុសលាវក្រោម បុសលាវលើ ល្វាទង ព្រះគន្លង ព្រៃកតាអាំ ព្រៃកកូវ ព្រៃកតា និងភូមិតាលួស ។ ឃុំបុសលាវ មានប្រជាពលរដ្ឋសរុប ១.៨៤២ គ្រួសារ ស្មើនឹង៧.៣៦៤នាក់ (ស្រី ៣.៥៦៩នាក់) ។ នៅក្នុងការវាយតម្លៃ VRA នេះមានប្រជាពលរដ្ឋចំនួន ២៥៣នាក់ ស្មើនឹង ៣.៥ ភាគរយនៃប្រជាពលរដ្ឋក្នុងឃុំ ។ ប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម ដាំដំណាំ ធ្វើស្រូវប្រាំងដោយប្រើប្រាស់ទឹកស្រោចស្រពពីបឹងជាច្រើន និងពីទំនប់ ព្រែក ទន្លេមួយចំនួនផងដែរ ។ ប្រាក់ចំណូលបន្ទាប់បន្សំផ្សេងៗទៀតរួមមានពីដំណាំរួមផ្សំដូចជាពោត ការនេសាទ ការចិញ្ចឹមសត្វជាដើម ។

មុនពេលធ្វើ VRA ការវិភាគនិន្នាការត្រូវបានធ្វើ ដើម្បីប៉ាន់ប្រមាណមើលថាតើប្រជាពលរដ្ឋបានកត់សម្គាល់នូវការផ្លាស់ប្តូរអាកាសធាតុនៅក្នុងអំឡុងពេលមួយ និងកំណត់ផងដែរគ្រោះភ័យនៃការប្រែប្រួលអាកាសធាតុណាមួយ ដែលបានប៉ះពាល់ប្រជាពលរដ្ឋបំផុតនៅក្នុងឃុំបុសលាវ ។ ការវិភាគនិន្នាការបានកំណត់គ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ ជាការគំរាមកំហែងដ៏ចម្បងចំពោះជីវភាពរស់នៅរបស់ពលរដ្ឋនៅក្នុងឃុំ ។

## ៥.២ ការវិភាគនិន្នាការនិងប្រភេទហានិភ័យនៃការប្រែប្រួលអាកាសធាតុ

អ្នកភូមិឃុំបុសលាវ បានធ្វើបង្ហាញពីគ្រោះមហន្តរាយចម្បង១ចំនួនបី ដែលមានផលប៉ះពាល់មកលើអាយុជីវិតនិងរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ដូចជាការបាត់បង់ព្រៃឈើ និងការរេចរឹលគុណភាពដីគឺជាបញ្ហាធ្ងន់ធ្ងរ ដែលធ្វើឱ្យដីបាត់បង់ជីជាតិទន្ទឹមនឹងការរំលោភយកដីធ្លីនិងការប្រើប្រាស់ធនធានធម្មជាតិដោយទូលំទូលាយ ដែលកំពុងធ្វើឱ្យបាត់បង់មូលធនធម្មជាតិជាបន្តទៀត ។

គ្រោះទឹកជំនន់ : ភាពញឹកញាប់និងរយៈពេលជំនន់នៅក្នុងភូមិគោលដៅមានកម្រិតខ្ពស់ ប៉ុន្តែទំនងជានៅមានកម្រិតថេរចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០មក ។ និយាយម្យ៉ាងទៀតថា កសិករមិនបានកត់សម្គាល់អំពីកំណើនធំដុំនៃទឹកជំនន់ឡើយនៅក្នុងរយៈពេល ៣០កន្លងមកនេះ ។ទោះជាយ៉ាងណាក៏ដោយ ទឹកជំនន់បានបង្កផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិតរបស់ពួកគាត់ ដោយបំផ្លាញដំណាំ ។ នៅកន្លែងនេះកសិករបានកត់សម្គាល់ដូចជាករណីទឹកជំនន់ដែរ ផលប៉ះពាល់មកលើដំណាំមានកម្រិតខ្ពស់ ប៉ុន្តែមានកម្រិតថេរនៅក្នុងបណ្តាឆ្នាំកន្លងទៅ ។ និយាយម្យ៉ាងទៀតថាផលប៉ះពាល់មកលើដំណាំមានកម្រិតខ្ពស់ ប៉ុន្តែមានកម្រិតដូចគ្នានៅក្នុងរយៈពេល ២០ឆ្នាំកន្លងមកនេះ ។ បន្ថែមលើការបំផ្លាញដំណាំ ទឹកជំនន់ក៏ធ្វើឱ្យផ្លូវថ្នល់មិនអាចធ្វើដំណើរបានផងដែរ ដែលរវាំខានដល់ការធ្វើដំណើររបស់កសិករនិងសិស្សទៅសាលារៀន ។ ទឹកជំនន់កំណាច ក៏បំផ្លាញផ្ទះនិងសត្វរបស់ពួកគេផងដែរ ហើយទាំងមនុស្ស និងសត្វត្រូវបានជម្លៀសទៅទីទួលសុវត្ថិភាពដោយប្រើប្រាស់ទូក ។

គ្រោះរាំងស្ងួត : ភាពញឹកញាប់និងរយៈពេលរាំងស្ងួត ត្រូវបានកត់សម្គាល់ថាកំពុងកើនឡើងនៅក្នុងអំឡុងពេល៣០ឆ្នាំកន្លងមកនេះ ។ ផលប៉ះពាល់ពីគ្រោះរាំងស្ងួតមកលើដំណាំ ក៏ឆ្លុះបញ្ចាំងពីកំណើនភាពញឹកញាប់ និងរយៈពេលនៃការរាំងស្ងួតផងដែរ ។ នៅក្នុងភូមិខ្លះ ផលប៉ះពាល់ពីគ្រោះរាំងស្ងួតមកលើដំណាំ មានកម្រិតខ្ពស់ដូចជាផលប៉ះពាល់ពីទឹកជំនន់ដែរ ហើយនៅក្នុងភូមិខ្លះទៀតផលប៉ះពាល់ដោយគ្រោះរាំងស្ងួតអាចខ្ពស់ជាងដោយទឹកជំនន់ទៀតផង ។ គួរកត់សម្គាល់ថា ភូមិទាំងអស់បានកត់សម្គាល់អំពីផលប៉ះពាល់នៃទឹកជំនន់មកលើដំណាំថាមានកម្រិតខ្ពស់ខ្លាំងណាស់នៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ហើយប្រការនេះអាចកើតឡើងក្រោមឥទ្ធិពលនៃគ្រោះរាំងស្ងួត ដែលបានជួបប្រទះនៅក្នុងឆ្នាំ២០១១នេះ ។ ទោះជាយ៉ាងណាក៏ដោយ របកគំហើញទាំងនេះពិតជា-មាន ការពាក់ព័ន្ធជាមួយការសន្មត ដែលថាភាពធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ បានកើតមាននៅខេត្តក្រចេះសម្រាប់លក្ខខណ្ឌនៃទឹកជំនន់ ហើយភាពធន់ទ្រាំនឹងគ្រោះរាំងស្ងួតបានកើតមាននៅខេត្តព្រះវិហារ ។ នៅក្នុងករណីនេះ គម្រោងនេះត្រូវចូលរួមនៅក្នុងសកម្មភាពនានាដែលនាំយកសមត្ថភាពបន្សាំទៅនឹងទាំងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងខេត្តក្រចេះ ។

ខ្យល់ព្យុះ : ខ្យល់ព្យុះ ក្រោមរូបភាពជាភ្លៀងធ្លាក់យ៉ាងខ្លាំង និងមានខ្យល់ខ្លាំង ក៏ត្រូវបានកត់សម្គាល់ដោយភូមិខ្លះ១ផងដែរថាជាគ្រោះមហន្តរាយអាកាសធាតុ ដែលមានឥទ្ធិពលមកលើការរស់នៅរបស់ពួកគេ ។ មិនដូចករណីទឹកជំនន់ និងគ្រោះរាំងស្ងួតឡើយ អ្នកភូមិមិនត្រូវបានស្នើសុំឱ្យចាត់ជាលំដាប់នូវភាពញឹកញាប់នៃព្យុះឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានកត់សម្គាល់ថា ព្យុះបានបំផ្លាញផ្ទះសម្បែង និងនាំយកទៅជាមួយនូវទូករបស់ពួកគេ ។

## ៥.៣ ហានិភ័យនៃការប្រែប្រួលអាកាសធាតុនៅក្នុងឃុំបុសលាវ

សំណួរទី ១- តើអ្នកជួបប្រទះបញ្ហាអ្វីខ្លះ នៅពេលមានភាពរាំងស្ងួត? តើវាប៉ះពាល់ដល់ការរស់នៅរបស់អ្នកដូចម្តេចខ្លះ?

ផ្អែកលើកលទ្ធផល ចម្លើយដែលផ្តល់អោយដោយក្រុមស្ត្រី និងបុរស ពុំមានភាពខុសគ្នាខ្លាំងទេ។ ផ្នែក៦ (តាមលំដាប់នៃភាពសំខាន់) ត្រូវបានកំណត់ ដែលមានឥទ្ធិពលខ្លាំងដោយសារការប្រែប្រួលអាកាសធាតុ ជាពិសេសដោយគ្រោះរាំងស្ងួត និងការអូសបន្លាយនៃភាពរាំងស្ងួត :

១. ការខូចខាតដំណាំស្រូវ

២. ឥទ្ធិពលអវិជ្ជមានលើសុខភាពមនុស្ស

៣. ឥទ្ធិពលអវិជ្ជមាន លើសុខភាពសត្វ

៤. ខូចខាតដំណាំដទៃទៀត

៥. ឥទ្ធិពលអវិជ្ជមានលើធនធានទឹកសម្រាប់ធារាសាស្ត្រ

៦. ខូចហេដ្ឋារចនាសម្ព័ន្ធ (ទំនប់ និងផ្លូវថ្នល់)

### រូបភាពទី៥.១ : ឥទ្ធិពលបច្ចុប្បន្ននៃការប្រែប្រួលអាកាសធាតុក្នុងឃុំបុសលាវ



ដូចដែលបានបង្ហាញក្នុងរូបខាងលើក្រុមបុរសនិងស្ត្រីនៅក្នុងភូមិទាំង៨គិតថា ការប្រែប្រួលអាកាសធាតុគឺជាការគម្រាមកំហែងមួយដ៏ចម្បងទៅដល់ទិន្នផលស្រូវនិងសុខភាពមនុស្ស។ កសិករបានលើកឡើងថាគ្រោះរាំងស្ងួតធ្វើឱ្យសំណាបខ្លោចនិងងាប់ ចំណែកឯ ទឹកជំនន់រម្លើង និងបំផ្លាញសំណាបនៅក្នុងស្រែ។ លើសពីនេះ គ្រោះរាំងស្ងួតនៅចំពេលដែលស្រូវកំពុងឡើងខ្លួនបានប៉ះពាល់ការរីកលូតលាស់នៃគ្រាប់ស្រូវដែលនាំឱ្យទិន្នផលស្រូវមានការធ្លាក់ចុះ។ ចំណែកឯបញ្ហាសុខភាព មនុស្សវិញ កសិករសង្កត់ធ្ងន់ទៅលើទឹកជំនន់ដែលជាមូលហេតុនាំឱ្យមានការកើនឡើងនៃជម្ងឺគ្រុនចាញ់និងគ្រុនឈាម ដែលជម្ងឺទាំងពីរនេះចម្លងពីសត្វមូស។ ចំណុចទី២ ដែលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ គឺសុខភាពសត្វនិងបំផ្លាញនូវផលដំណាំដទៃទៀត។ ចំពោះផលដំណាំ កសិករបានលើកឡើងថាគ្រោះរាំងស្ងួតនិងទឹកជំនន់ បានបំផ្លាញ បន្លែ ពោត ល្ងនិងចេក ដែលបានដាំនៅក្នុងតំបន់គោលដៅ។ គ្រោះរាំងស្ងួត និងកម្តៅខ្លាំងបានធ្វើឱ្យគោ ក្របី ជ្រូក មាន់ ទា ឈឺនិងងាប់កាន់តែច្រើន។ លើសពីនេះ ទឹកជំនន់និងខ្យល់ព្យុះ ក៏បានហូរនិងបក់គួចយកសត្វពាហនៈជាពិសេសនៅតំបន់ដែលកសិករពុំមានទីទួលជាជម្រកដល់សត្វទាំងនោះ។

ចំណុចទី៣ ដែលប៉ះពាល់ខ្លាំងដោយការប្រែប្រួលអាកាសធាតុគឺធនធានទឹក។ ទោះបីជាខេត្តក្រចេះមានបឹងធម្មជាតិ និងទំនប់មួយចំនួនក៏ដោយ គ្រោះរាំងស្ងួតបានធ្វើធនធានទឹករីងស្ងួត។ កសិករខ្លះបាននិយាយថា ទំនប់មានការរីងស្ងួតដោយសារតែវាមានជម្រៅរាក់ពេក ដោយមានការហូរចូលនូវដីល្បាប់ ដែលមូលហេតុមក ពីមានការកាប់ព្រៃឈើ។ទំនប់ដែលរាក់ជាងមុនអាចស្តុកទឹកតិចជាងមុន ហើយរីងស្ងួតនៅក្នុងពេលមានគ្រោះរាំងស្ងួតនិងក្នុងរដូវប្រាំង។ ចំណុចទី៤ គឺគ្រោះទឹកជំនន់បានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធជនបទនៅក្នុងតំបន់គោលដៅ។ ទំនប់ ផ្លូវថ្នល់ រួមទាំងផ្ទះប្រជាពលរដ្ឋផងត្រូវបានបំផ្លាញ។ ទំនប់ដែលខូចខាត មិនអាចស្តុកទឹកបានរីឯផ្លូវថ្នល់ដែល លិចលង់បានក្លាយជាឧបសគ្គ ដល់ការធ្វើដំណើររបស់កុមារទៅសាលារៀន និងដល់កសិករក្នុងការនាំទំនិញទៅលក់នៅទីផ្សារ។

ចម្លើយនៅក្នុងការវាយតម្លៃ VRA ចំពោះសំណួរទី១នេះ បានបង្ហាញពីគំនិតខុសគ្នារវាងក្រុមបុរសនិងស្ត្រី ចំពោះឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទៅលើប្រព័ន្ធធារាសាស្ត្រ សុខភាពសត្វ និងហេដ្ឋារចនាសម្ព័នជនបទ។ ក្រុមបុរសគិតថាការប្រែប្រួល-អាកាសធាតុ ជាពិសេសគ្រោះរាំងស្ងួតបានធ្វើឱ្យប្រព័ន្ធធារាសាស្ត្ររាំងស្ងួតនៅក្នុងតំបន់គោលដៅ។ លើសពីនេះ មានបុរសច្រើនជាងស្ត្រីគិតថា គ្រោះរាំងស្ងួតនិងកម្តៅបានធ្វើឱ្យសត្វឈឺនិងងាប់។ ដោយឡែកក្រុមស្ត្រីវិញនិយាយថា ទឹកជំនន់និងខ្យល់ព្យុះ គឺជាមូលហេតុបំផ្លាញនូវប្រព័ន្ធប្រឡាយទឹក ផ្លូវថ្នល់ និងផ្ទះសម្បែង។

## តារាង ៥.១: តារាងសង្ខេបពីចម្លើយដែលឆ្លើយញឹកញាប់សម្រាប់សំណួរទី១

| ហេតុផលសម្រាប់ចម្លើយអវិជ្ជមាន | សំណួរទី១ | ហេតុផលសម្រាប់ចម្លើយវិជ្ជមាន |
|---|---|---|
| ១. ការរលួយសំណាប ស្រូវ និងដំណាំផ្សេងទៀត ដោយសារតែទឹកជំនន់ គ្រោះរាំងស្ងួត និងការបំផ្លាញ ដោយសត្វល្អិត។<br>២. ឥទ្ធិពលអវិជ្ជមានមកលើសុខភាពប្រជាជន។<br>៣. ឥទ្ធិពលអវិជ្ជមានមកលើសុខភាពសត្វ។<br>៤. ធនធានទឹករីងស្ងួត ដែលមានឥទ្ធិពលមកលើបរិមាណនិងគុណភាពទឹកសម្រាប់ការស្រោចស្រព និងការប្រើប្រាស់តាមគ្រួសារ។<br>៥. ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ (ទំនប់និងផ្លូវថ្នល់)។<br>៦. ការខូចខាតផ្ទះ និងបាត់បង់ទូក ដោយសារខ្យល់ព្យុះ។<br>៧. គ្មានពូជសម្រាប់ស្ទូង ក្រោយគ្រោះរាំងស្ងួត និងជំនន់។<br>៨. ប្រជាជន សិស្សសាលា និងសត្វមិនអាចធ្វើដំណើរបានដោយសារតែទឹកជំនន់។ | តើអ្នកបានជួបប្រទះឃើញអ្វី បណ្តាលពីការប្រែប្រួលអាកាសធាតុ? និងតើវាមានឥទ្ធិពលអ្វីខ្លះមកលើការរស់នៅរបស់អ្នក?<br>ពិន្ទុ<br>៣.៨៧<br><br>ធ្វើបែបណាដើម្បីអាចកែលម្អពិន្ទុនេះ?<br>១. ស្តារ/សាងសង់ទំនប់ និងស្រះសម្រាប់ស្រោចស្រពនៅពេលរាំងស្ងួត។<br>២. ជួសជុលផ្លូវថ្នល់ និងស្ពានឡើងវិញ។<br>៣. ផ្តល់ការបណ្តុះបណ្តាលអំពីការដាំដំណាំ និងធ្វើសួនបន្លែ។<br>៤. បង្កើនលទ្ធភាពទទួលបានពូជស្រូវស្រាល ដែលផ្តល់ទិន្នផលខ្ពស់ និងធន់នឹងភាពរាំងស្ងួត។<br>៥. ផ្សព្វផ្សាយអំពីការចិញ្ចឹមសត្វនិងត្រី។<br>៦. ផ្តល់ធុងចម្រោះ។<br>៧. បង្កើនការផ្តល់សេវាកម្មសុខភាពសត្វនិងចាក់ថ្នាំ បង្ការ (VAHW)។ | ១. មានបុគ្គលិកសុខភាពសត្វតាមភូមិខ្លះៗ (VAHW)។<br>២. មាន NGOs ជាច្រើនដែលធ្វើការនៅក្នុងតំបន់គោលដៅដោយដោះស្រាយកង្វល់ទាំងនេះខ្លះៗ។<br>៣. មានមណ្ឌលសុខភាព ទោះបីខ្លះស្ថិតនៅឆ្ងាយក៏ដោយ។<br>៤. ភូមិខ្លះបានទទួលថ្នាំបង្ការ ជម្រក និងមានទីទួលសុវត្ថិភាព។<br>៥. មានទំនប់ និងបឹងជាច្រើន។<br>៦. កសិករបានទទួលពូជ និងសេវាកម្មផ្សព្វផ្សាយពីមន្ទីរកសិកម្មខេត្ត។ |

ផ្នែកកណ្តាលនៃតារាង បង្ហាញពីពិន្ទុ VRA ចំនួន ៣.៨៧ សម្រាប់សំណួរទី១ នៅលើមាត្រដ្ឋាន ១ ដល់៥។ នៅខាងក្រោម-ពិន្ទុនោះ ទម្រង់ហាស់ បង្ហាញពីគំនិតរបស់កសិករក្នុងការកែលម្អពិន្ទុ ឱ្យកាន់តែប្រសើរឡើង។ ចម្លើយសង្ខេបអំពីពិន្ទុនៃសំណួរទី ១ ទី២ និងទី៣ រួមទាំងចម្លើយវិជ្ជមានអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ត្រូវបានពិភាក្សានៅផ្នែកខាងក្រោម។

សំណួរទី២ : តើមានអ្វីកើតឡើង ប្រសិនបើគ្រោះរាំងស្ងួតកើតញឹកញាប់ទ្វេរដង? តើវាប៉ះពាល់អ្នកនិងសហគមន៍របស់អ្នកយ៉ាងដូចម្តេច?

សំណួរទី២ ព្យាយាមកំណត់ថាតើការរស់នៅនិងជីវភាពរស់នៅនឹងទទួលរងឥទ្ធិពលយ៉ាងដូចម្តេច ប្រសិនបើមានការកើនឡើងនូវគ្រោះថ្នាក់ និងភាពញឹកញាប់នៃគ្រោះភ័យអាកាសធាតុដូចជាគ្រោះទឹកជំនន់និងរាំងស្ងួត ។ នៅក្នុងលំដាប់នៃភាពសំខាន់ កសិករមានអារម្មណ៍ថាការកើននូវគ្រោះរាំងស្ងួត នឹងមានឥទ្ធិពលអវិជ្ជមាន លើផ្នែកនានាដូចខាងក្រោម :

១. ឥទ្ធិពលអវិជ្ជមានលើសុខភាពមនុស្ស និងសត្វ

២. ប្រជាពលរដ្ឋកាន់តែជួបកង្វះខាតស្បៀងកាន់តែខ្លាំង ដោយសារទិន្នផលស្រូវកាន់តែថយចុះ

៣. កាត់បន្ថយចំណូល ដោយសារទិន្នផលស្រូវកាន់តែថយចុះ

៤. កាន់តែខ្វះខាតទឹកសម្រាប់មនុស្ស និងសត្វ

## រូបភាពទី៥.២ : ឥទ្ធិពលនៃកំណើនការប្រែប្រួលអាកាសធាតុ




រូបខាងលើបង្ហាញពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ។ ទីមួយអ្នកភូមិបានដាក់ពិន្ទុខ្ពស់ជាងគេចំពោះទឹកជំនន់និងគ្រោះរាំងស្ងួត ដែលកើតចេញពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ហើយបានបំផ្លាញសុខភាពមនុស្សនិងសត្វ ។ ទីពីរ គឺកសិករបានប្រមើមើលថានឹងមាននូវបញ្ហាសន្តិសុខស្បៀង ប្រសិនបើមានការកើនឡើងនូវចំនួន គ្រោះទឹកជំនន់និងរាំងស្ងួតដែលកើតចេញពីការប្រែ-ប្រួលអាកាសធាតុ ។ មូលហេតុនៃអសន្តិសុខស្បៀង គឺបណ្តាលមកពីការធ្លាក់ចុះនៃទិន្នផលស្រូវ ។ ទីបី គឺការធ្លាក់ចុះនៃទិន្នផលស្រូវនេះក៏ធ្វើឱ្យប្រាក់ចំណូលរបស់ពួកគេ ធ្លាក់ចុះផងដែរ ។ ទីបួន កសិករក៏គិតឃើញផងដែរថា ធនធានទឹកសម្រាប់ការដាំដំណាំ នឹងកាន់តែខ្សត់ទៅ ប្រសិនបើមានគ្រោះរាំងស្ងួតកើតឡើងនោះ ។

នៅក្នុងចម្លើយរបស់កសិករ បុរសនិងស្ត្រី គឺមានភាពខុសប្លែកគ្នាទៅតាមលក្ខណៈយេនឌ័រ ។ ឧទាហរណ៍ ក្រុមស្ត្រីមកពីភូមិចំនួន៤ បានគិតថាការកើនឡើងនៃចំនួនគ្រោះធម្មជាតិ អាចធ្វើឱ្យខ្វះទឹកសម្រាប់ការប្រើប្រាស់របស់មនុស្សនិងសត្វ ។ ដោយឡែកក្រុមកសិករពុំបានលើកឡើងពីបញ្ហានេះទេ ។ ផ្ទុយទៅវិញ ក្រុមបុរស មើលឃើញ អំពីបញ្ហាទាក់ទងនឹងជម្រកសត្វ ដូចជាការស្វែងរកទីទួលនៅពេលមានគ្រោះទឹកជំនន់កើនឡើងញឹកញាប់ទៅវិញ ។ ចំពោះបញ្ហាជម្រកសត្វនេះមានស្ត្រីតែមួយក្រុមគត់ដែលចាត់ទុកថាវាជាបញ្ហា ។

## តារាង ៥.២: តារាងសង្ខេបពីចម្លើយដែលឆ្លើយញឹកញាប់សម្រាប់សំណួរទី២

| ហេតុផលសម្រាប់ចម្លើយអវិជ្ជមាន | សំណួរទី២ | ហេតុផលសម្រាប់ចម្លើយវិជ្ជមាន |
|---|---|---|
| ១. ធនធានទឹកកាន់តែរីងស្ងួត ដែលនាំឱ្យខ្វះទឹកសម្រាប់ស្រោចស្រព និងការថយចុះគុណភាពទឹកក្នុងមូលដ្ឋាន សម្រាប់ការស្រោចស្រព និងប្រើប្រាស់ក្នុងគ្រួសារ ។<br>២. ការខូចខាតដំណាំកាន់តែច្រើន នាំឱ្យមានទិន្នផលទាប ខ្វះស្បៀង ខ្វះប្រាក់ និងជាប់បំណុល ។<br>៣. សុខភាពរបស់មនុស្សកាន់តែច្រើននឹងរងឥទ្ធិពលអវិជ្ជមាន ។<br>៤. សុខភាពសត្វនឹងរងឥទ្ធិពលអវិជ្ជមាន ។<br>៥. តម្រូវការជម្រកកាន់តែច្រើនសម្រាប់ភៀសខ្លួននៅពេលមានជំនន់ ។ | តើមានអ្វីកើតឡើង ប្រសិនបើគ្រោះរាំងស្ងួត និងទឹកជំនន់ កាន់តែអាក្រក់?<br>ពិន្ទុ<br>៤.៧៥<br><br>ធ្វើបែបណាដើម្បីអាចកែលម្អពិន្ទុនេះ?<br>១. ស្ពាន/សង់ទំនប់ និងស្រះសម្រាប់ស្រោចស្រព ។<br>២. បង្កើនការប្រើប្រាស់ពូជស្រូវស្រាល ដែលផ្តល់ទិន្នផលខ្ពស់ និងធន់ចំពោះភាពរាំងស្ងួត ។<br>៣. ផ្តល់បច្ចេកទេសដាំបន្លែ ចិញ្ចឹមសត្វ និងវារីវប្បកម្ម ។<br>៤. ផ្តល់កូនត្រី ពូជសត្វ និងបន្លែ ដែលធន់ទ្រាំនឹងអាកាសធាតុ ។ | ១. មាន NGOs ជាច្រើននៅក្នុងតំបន់គោលដៅ ដែលធ្វើការដោះស្រាយកង្វល់ទាំងនេះខ្លះៗ ។<br>២. មានការគាំទ្រពីរដ្ឋាភិបាលតាមរយៈ មន្ទីរកសិកម្ម មន្ទីរធនធានទឹកនិងឧតុនិយម មន្ទីរសុខាភិបាល ។ល ។<br>៣. មានបុគ្គលិកសុខភាពសត្វភូមិខ្លះៗ (VAHW) ។<br>៤. មានធនាគារជនបទខ្លះៗ ក្រុមសន្សំប្រាក់ មូលនិធិបង្វិលកំពុងដំណើរការនៅ-ក្នុងភូមិនានា ។<br>៦. ភូមិខ្លះមានជម្រកសុវត្ថិភាព ។<br>៧. មានមណ្ឌលសុខភាពខ្លះៗ ។ |

សរុបមក សម្រាប់សំណួរទី១កសិករនៅក្នុងឃុំបុសលាវ មានអារម្មណ៍ថាភាពងាយរងគ្រោះបច្ចុប្បន្នរបស់ពួកគេ គឺមានពិន្ទុ VRA ៣.៨៧ ហើយពិន្ទុនេះអាចកើន ឡើងរហូតដល់ ៤.៧៥ (សំណួរទី២) ប្រសិនបើគ្រោះរាំងស្ងួត និងទឹកជំនន់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ មានការកើនឡើង ។ របៀបកែលម្អពិន្ទុនេះ នឹងមានពិភាក្សានៅផ្នែកខាងក្រោម ។

សំណួរទី ៣: តើអ្វីខ្លះជាឧបសគ្គសម្រាប់អ្នក ក្នុងការបន្សាំទៅនឹងកំណើនគ្រោះរាំងស្ងួត? តើអ្នកនិងសហគមន៍របស់អ្នក មានមធ្យោបាយអ្វីខ្លះសម្រាប់គ្រប់គ្រងបញ្ហានានាទាំងនេះ ដែលកើតមានកាន់តែញឹកញាប់?

ឧបសគ្គចម្បងៗរួមមាន :

១. កង្វះពូជស្រូវដែលធន់នឹងគ្រោះរាំងស្ងួត និងទឹកជំនន់

២. កង្វះបច្ចេកទេសកសិកម្ម

៣. កង្វះធនធានទឹក

៤. កង្វះប្រាក់

៥. កង្វះព័ត៌មាន

## រូបភាព ៥.៣ : ឧបសគ្គចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ




មិនដូចសំណួរទី១ និងទី២ឡើយ ចម្លើយអំពីឧបសគ្គដែលរារាំងកសិករពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មិនសូវដូចគ្នាឡើយ។ ទោះជាយ៉ាងណាក៏ដោយ កង្វះពូជស្រូវដែលធន់នឹងគ្រោះរាំងស្ងួតនិងទឹកជំនន់ ត្រូវបានកសិករចំនួន៧ភូមិ មើលឃើញថាជាបញ្ហាធំបំផុត។ ហេតុដូចនេះកសិករគិតថាភាពងាយរងគ្រោះរបស់ពួកគេអាចកាត់បន្ថយបាន ប្រសិនបើមានពូជស្រូវដែលមានទិន្នផលខ្ពស់ ឆាប់បានផល និងធន់ទៅនឹងគ្រោះរាំងស្ងួតនិងទឹកជំនន់។ បន្ថែមពីលើពូជស្រូវដែលធន់នឹងគ្រោះធម្មជាតិនេះ កសិករក៏ត្រូវការផងដែរនូវបច្ចេកទេសកសិកម្ម។ កសិករខ្លះបានត្អូញត្អែរថា ពួកគេពុំដែលបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មពីរាជរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល។ កសិករទាមទាឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មថ្មីៗក្នុងការដាំស្រូវ ដាំបន្លែ

ចិញ្ចឹមសត្វ និងចិញ្ចឹមត្រីជាដើម ។

កង្វះខាតទឹកសម្រាប់ប្រព័ន្ធធារាសាស្ត្រទំនប់និងត្រពាំងសម្រាប់គ្រួសារគឺជាឧបសគ្គមួយទៀតដ៏សំខាន់ដែលធ្វើឱ្យកសិករមិនអាចបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្ម ។ បើសិនជាមានទឹក កសិករអាចធ្វើស្រែនិងដាំដំណាំបានពេលមានគ្រោះរាំងស្ងួតឬនៅក្នុងរដូវប្រាំង ។ គួរកត់សម្គាល់ដែរថា កសិករនៅក្នុងភូមិបុសលាវនេះរស់នៅក្បែរទំនប់ទឹកនិងបឹងធម្មជាតិ ក៏ប៉ុន្តែប្រភពទឹកទាំងនោះតែងតែរីងស្ងួតនិងចុះរាក់នៅរដូវប្រាំង ។ លើសពីនេះ ប្រឡាយនាំទឹកទៅដល់ស្រែកសិករក៏ចុះរាក់ផងដែរ ដោយ-សារមានការច្រោះដីចូល ។ ចំណែកឯបញ្ហាមួយទៀតគឺកង្វះខាតថវិកា ។ កសិករបានលើកឡើងថា ពួកគេខ្វះថវិកាទិញពូជស្រូវដែលធន់នឹងគ្រោះធម្មជាតិ អនុវត្តពិពិធកម្មកសិកម្ម ទិញប្រេងបូមទឹក និងទិញទូកសម្រាប់ប្រើប្រាស់នៅពេលមានទឹកជំនន់ ។ បញ្ហាចុងក្រោយគឺកង្វះខាតព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ។ កង្វះខាតព័ត៌មានទាំងនោះរួមមានចំណេះដឹងអំពីការអនុវត្តបច្ចេកទេសកសិកម្មវិធីសាស្ត្រដោះស្រាយក្នុងពេលមានទឹកជំនន់ និងខ្យល់ព្យុះ រួមទាំងព័ត៌មានប្រកាសដំណឹងជាមុនអំពីទឹកជំនន់ និងគ្រោះរាំងស្ងួត ។

## តារាង ៥.៣: តារាងសង្ខេបពីចម្លើយដែលឆ្លើយញឹកញាប់សម្រាប់សំណួរទី៣

| ហេតុផលសម្រាប់ចម្លើយអវិជ្ជមាន | សំណួរទី៣ | ហេតុផលសម្រាប់ចម្លើយវិជ្ជមាន |
|---|---|---|
| ១. ខ្វះពូជស្រូវដែលធន់នឹងគ្រោះរាំងស្ងួត និងទឹកជំនន់ ។<br>២. ខ្វះប្រាក់ដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ។<br>៣. ខ្វះបច្ចេកទេសដាំដំណាំ និងចិញ្ចឹមសត្វ ។<br>៤. ខ្វះធនធានទឹកសម្រាប់ស្រោចស្រព នៅពេលរាំងស្ងួត ។<br>៥. ខ្វះចំណេះដឹងពីការដាំដំណាំ ដែលអាចទប់ទល់នឹងគ្រោះរាំងស្ងួត និងទឹកជំនន់ (ផ្សព្វផ្សាយ).<br>៦. ខ្វះទូកសម្រាប់ធ្វើដំណើរនៅពេលមានទឹកជំនន់ ។ | តើអ្វីខ្លះដែលរារាំងអ្នកពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ?<br>ពិន្ទុ<br>៤.១៨<br><br>ធ្វើបែបណាដើម្បីអាចកែលម្អពិន្ទុនេះ?<br>១. បង្កើនការប្រើប្រាស់ពូជស្រូវស្រាល ដែលផ្តល់ទិន្នផលខ្ពស់និងធន់ទ្រាំចំពោះភាពរាំងស្ងួត ។<br>២. ទទួលបានបច្ចេកទេសដាំដំណាំស្រូវ ឈើហូបផ្លែ ចិញ្ចឹមសត្វនិងត្រី ។<br>៣. ស្តារ/បង្កើតបឹង ទំនប់និងស្រះ និងពង្រីកទ្វារទឹកសម្រាប់ស្រោចស្រព ។<br>៤. ពង្រឹងក្រុមកសិករប្រើប្រាស់ទឹក ។<br>៥. ផ្តល់ព័ត៌មានប្រកាសអាសន្ន ។<br>៦. ផ្តល់ទឹកស្អាតតាមរយៈអណ្តូង ធុងចម្រោះ និងសេវាកម្មអនាម័យ ។ | ១. មន្ទីរធនធានទឹកនិងឧតុនិយម ជួសជុលទំនប់ខ្លះៗឡើងវិញ ។<br>២. មន្ទីរកសិកម្មផ្តល់ពូជនិងការបណ្តុះបណ្តាលខ្លះៗ អំពីការដាំស្រូវនិងបន្លែ ។<br>៣. ព័ត៌មានខ្លះៗអំពីការប្រែប្រួលអាកាសធាតុ មានចាក់ផ្សាយតាមវិទ្យុខេត្ត ។<br>៤. កសិករខ្លះកំពុងប្រើប្រាស់ពូជកែលម្អ ។<br>៥. វត្តមានទំនប់និងបឹង ។<br>៦. NGOs ខ្លះកំពុងផ្តល់ការអប់រំ ពូជស្រូវ និងផ្សព្វផ្សាយ ។ល ។<br>៧. ការគាំទ្រពីរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្ម មន្ទីរធនធានទឹកនិងឧតុនិយម មន្ទីរសុខាភិបាល ។ល ។ |

ទម្រង់ហាស់ខាងលើបង្ហាញថា ពិន្ទុ VRA នៃសំណួរទី៣ គឺ ៤.១៨។ ពិន្ទុនេះមានន័យថា កសិករនៅក្នុងឃុំបុសលាវយល់ឃើញថា ពួកគេមានភាពងាយរងគ្រោះខ្ពស់ បើគិតពីសមត្ថភាពពួកគេក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

សំណួរ ៤- ចូរដាក់ពិន្ទុអំពីទំនុកចិត្តរបស់អ្នកថា (សកម្មភាពនៃគម្រោងនេះ) នឹងបន្តក្រោយពេលគម្រោងនេះចប់? ដូចករណីនៅព្រះវិហារដែរ សំណួរទីបួន មិនត្រូវបានពិចារណាឡើយ។

## ៥.៣.១ មូលហេតុនៃចម្លើយវិជ្ជមាន

កសិករនៅក្នុងឃុំបុសលាវ បានលើកឡើងនូវវិស័យសំខាន់ៗ សម្រាប់កាត់បន្ថយនូវឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ រួមមាន : (សូមមើលរូបខាងក្រោម)

១. សេវាកម្មផ្តល់ដោយរាជរដ្ឋាភិបាល

២. វត្តមាន និងសេវាកម្មរបស់អង្គការក្រៅរដ្ឋាភិបាល

៣. ពេទ្យសត្វភូមិ

៤. សេវាកម្មសុខភាព

៥. មជ្ឈមណ្ឌលស្នាក់នៅពេលមានគ្រោះធម្មជាតិ

៦. ទំនប់ និងបឹងធម្មជាតិ

៧. ប្រាក់កម្ចី

រូបភាពទី៥.៤ : កត្តាកាត់បន្ថយភាពផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ



កសិករនៅក្នុងឃុំបុសលាវមានជំនឿយ៉ាងមុតមាំថា សកម្មភាពដែលចូលរួមអនុវត្តដោយស្ថាប័ននានា របស់រាជរដ្ឋាភិបាល ពិតជាអាចជួយកាត់បន្ថយនូវផលប៉ះពាល់ ដែលកើតចេញពីការប្រែប្រួលអាកាសធាតុ។ មន្ទីរកសិកម្ម និងមន្ទីរធនធានទឹក ត្រូវបាន គេចាត់ទុកថាជាស្ថាប័នរដ្ឋដ៏សំខាន់ក្នុងការផ្តល់ពូជស្រូវនិងបច្ចេកទេសកសិកម្ម ស្តារប្រព័ន្ធធារាសាស្ត្រនិងបូមទឹក។ ដូចគ្នានេះដែរ កសិករក៏ពេញចិត្តនឹងសេវាកម្ម ដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលនានាដែលកំពុងធ្វើការនៅក្នុងតំបន់។ អង្គការជាច្រើន[២] បាន ផ្តល់ជាជំនួយមនុស្សធម៌ ដូចជាទូក ផ្ទះ ធុងចម្រោះទឹក ពូជស្រូវ សំណាញ់បង់ត្រីជាដើម។ អង្គការខ្លះទៀតបានពង្រីកសេវាកម្មរបស់ខ្លួន ទៅលើការផ្តល់បច្ចេកទេសកសិកម្ម ការអប់រំសុខភាព និងប្រាក់កម្ចីជាដើម។ ក្នុងឃុំបុសលាវ មានចំនួន អង្គការក្រៅរដ្ឋាភិបាលច្រើន ជាងនៅឃុំជាំក្សាន្ត ហើយអង្គការទាំងនោះផ្តោតទៅលើ សកម្មភាពនៃការគ្រប់គ្រងហានិភ័យនៃ គ្រោះមហន្តរាយ ដោយសារតែតំបន់ នេះមានគ្រោះទឹកជំនន់ និងខ្យល់ព្យុះជាញឹកញាប់។

ភូមិភាគច្រើននៅក្នុងឃុំ មានវត្តមានពេទ្យសត្វសម្រាប់ផ្តល់សេវាកម្មសុខភាពសត្វ។ លើសពីនេះ ភូមិទាំងនោះក៏ទទួល បាននូវសេវាកម្មពីមណ្ឌលសុខភាពឃុំផងដែរ បើទោះអ្នកភូមិខ្លះបានលើកឡើងថាមណ្ឌលសុខភាពនោះមានចម្ងាយឆ្ងាយក៏ដោយ។ មជ្ឈមណ្ឌលអប់រំ ក៏ត្រូវបានរៀបចំដោយអង្គការក្រៅរដ្ឋាភិបាលផងដែរ ហើយមណ្ឌលទាំងនោះបានក្លាយទៅជាជម្រកមនុស្ស និង-សត្វ នៅក្នុងពេលមានគ្រោះទឹកជំនន់។ គួរកត់សម្គាល់ផងដែរ អ្នកភូមិទាំងអស់ដែលបានសម្ភាសបានលើកឡើងថា ពួកគេអាចជម្លៀស ទៅរកមជ្ឈមណ្ឌលស្នាក់នៅពេលមានគ្រោះធម្មជាតិ។

តំបន់គោលដៅនេះមានបឹងធម្មជាតិ អូរ និងទំនប់ ហើយកសិករយល់ឃើញថាធនធានទាំងនេះមានសារៈសំខាន់ណាស់ សម្រាប់ជួយពួកគេ នៅពេលមានគ្រោះរាំងស្ងួត និងសម្រាប់ធ្វើស្រែប្រាំង។ កសិករក៏បានលើកឡើងផងដែរថា ពួកគេបានទទួលប្រាក់ កម្ចីពីធនាគារផ្លូវការមួយចំនួនដូចជា ធនាគារអេស៊ីលីដា អម្រិត ក្រុមប្រាក់សន្សំ និងប្រាក់កម្ចីដែលផ្តល់ដោយអង្គការមិនមែន រដ្ឋាភិបាល រួមមាន អង្គការ ប៉ាដិក ប្រាសាក់ ជាដើម។

## ៥.៤ ពិន្ទុនៅក្នុង VRA

ដោយផ្អែកលើតួលេខមធ្យមអំពី VRA នៅក្នុងភូមិទាំងប្រាំបី សន្ទស្សន៍ VRA សម្រាប់ឃុំបុសលាវគឺ ៤.២៨ ដែលបង្ហាញ ថាភូមិនេះងាយរងគ្រោះបំផុតដោយសារទឹកជំនន់ គ្រោះរាំងស្ងួតនិងព្យុះ។ ភូមិទាំងអស់ មានតួលេខ VRA ជាមធ្យម ខ្ពស់ជាង ៤ ដោយភូមិព្រែកតាថុង មាន ៤.០៣ ដែលងាយរងគ្រោះតិចតួចជាងគេក្នុងចំណោម ភូមិទាំងប្រាំ និងបុសលាវលើ និងព្រែកថ្លូវមាន ៤.៥៧ ដែលងាយរងគ្រោះបំផុតក្នុងចំណោមភូមិទាំងប្រាំបី។ លទ្ធផលនានាបង្ហាញថា អ្នកភូមិនានាដែលបានចូលរួមនៅក្នុង VRA គិតថាភាពងាយរងគ្រោះ នឹងកើនឡើង ជិតដល់ចំណុចអតិបរមា ៥ ប្រសិនបើមានកំណើនទឹកជំនន់ គ្រោះរាំងស្ងួតនិងព្យុះ។

២ អង្គការដែលប្រតិបត្តការនៅក្នុងតំបន់រួមមាន : កាកបាទក្រហមកម្ពុជា អុកស្វាម ប៉ាដិក ACK CHE CGA PFP ACUKនិង SCS ។

### ៥.៤.១ ការកែលម្អពិន្ទុ VRA

បន្ទាប់ពីដាក់ពិន្ទុលើភាពងាយរងគ្រោះរួចមក កសិករត្រូវបានគេស្នើឱ្យលើកសំណួមពរ ដើម្បីកែលម្អភាពងាយរងគ្រោះរបស់ពួកគេ ។ ខាងក្រោមនេះគឺជាតារាងចម្លើយសង្ខេប ដែលកសិករឆ្លើយញឹកញាប់ ។

## រូបភាពទី៥.៤: វិធីសាស្ត្រកែលម្អពិន្ទុ VRA




តាមលំដាប់នៃសារៈសំខាន់ កសិករនៅឃុំបុសលាវ មានអារម្មណ៍ថាពិន្ទុសម្រាប់ VRA អាចកែលម្អបាន ដោយផ្តោតលើផ្នែកនានាដូចតទៅ :

១. ការស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រព ប្រឡាយ និងបឹងធម្មជាតិ

២. ការផ្តល់លទ្ធភាពក្នុងការប្រើប្រាស់ពូជស្រូវកែលម្អខុសៗគ្នា

៣. ការបណ្តុះបណ្តាលអំពីបច្ចេកទេសថ្មីៗខាងកសិកម្ម

៤. ការផ្តល់សេវាកម្មសុខភាពសត្វ

៥. ការគាំទ្រផ្នែកស្ថាប័នពីសំណាក់រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល

បើតាមរូបភាពខាងលើ ទាំងក្រុមបុរសនិងស្ត្រីមកពីគ្រប់ភូមិទាំងអស់បានលើកឡើងថា ភាពងាយរងគ្រោះនៅក្នុងវិស័យកសិកម្មអាចកែលម្អបាន ប្រសិនបើប្រព័ន្ធធារាសាស្ត្រត្រូវបានគេស្តារឡើងវិញ ។ ប្រព័ន្ធធារាសាស្ត្រនៅទីនេះគឺសំដៅទៅលើបឹងធម្មជាតិ ទំនប់សាងសង់ដោយកម្លាំងមនុស្ស ទំនប់ទឹកនិងទ្វារទឹក ។ ចំណុចនេះមានភាពសមហេតុផលដោយសារនៅខេត្តក្រចេះមានដំណាំស្រូវដែលទិន្នផលវាធ្លាក់ចុះនៅរដូវប្រាំង ហើយទាមទារនូវប្រព័ន្ធធារាសាស្ត្រ ។ ដូចនៅក្នុងខេត្តព្រះវិហារដែរ ការមានលទ្ធភាពប្រើប្រាស់ពូជស្រូវកែលម្អខុសៗគ្នាគឺជាកត្តាសំខាន់ទីពីរ ក្នុងការកែលម្អសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្ម ។ ការប្រើប្រាស់ពូជស្រូវកែលម្អខុសៗគ្នា រួមមានពូជដែលធន់នឹងភាពរាំងស្ងួត បានផលក្នុងរយៈពេលខ្លីនិងផ្តល់

ទិន្នផលខ្ពស់ ។ កសិករនៅភូមិបុសលាវក្រោម ក៏បានស្នើនូវពូជស្រូវដែលមានតម្លៃខ្ពស់ ។ ពូជទាំងនោះគឺជាពូជ ស្រូវក្រអូប ដែលមាន-តម្លៃ និងសម្រាប់លក់នៅទីផ្សារទីក្រុង ។

ការផ្តោតលើ ការមានលទ្ធភាពប្រើប្រាស់ពូជស្រូវកែលម្អខុសៗគ្នានិងធនធានទឹក គឺជាវិធីចម្បងនៃការកែលម្អពិន្ទុ VRA ឆ្លុះបញ្ចាំងអំពីឧបសគ្គចម្បងៗចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (សូមមើលតារាងខាងក្រោម) និងចំណាប់អារម្មណ៍ជា-ទូទៅផងដែរថា ការប្រែប្រួលអាកាសធាតុ មានផលប៉ះពាល់អវិជ្ជមានមកលើធនធានទឹក ដូចមានគូសបញ្ជាក់នៅក្នុងសំណួរទី១ និង-ទី២ ។

ចំណុចសំខាន់ទី៣ក្នុងការកែលម្អពិន្ទុគឺការប្រើប្រាស់បច្ចេកទេសថ្មីៗខាងកសិកម្មនៅក្នុងដំណាំស្រូវ ។បច្ចេសទេសនៅទាំងនោះត្រូវបានប្រើប្រាស់ ដើម្បីធ្វើពិពិធកម្មកសិកម្មដូចជាដាំបន្លែជាច្រើនមុខខុសៗគ្នា ការចិញ្ចឹមសត្វនិងចិញ្ចឹមត្រី ។ លើសពីនេះកសិករខ្លះលើកឡើងពីបច្ចេកទេសកម្ចាត់សត្វល្អិតនិងវិធីធ្វើជីកំប៉ុស្តិ៍ជាដើម ។ចំណុចទី៤គឺកសិករគិតថាការទទួលបានសេវាកម្មសុខភាពសត្វអាចកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ។ ការថែទាំសុខភាពសត្វរួមមានការចាក់វ៉ាក់សាំង បង្កើតឱ្យមានភ្នាក់ងារសុខភាពសត្វភូមិ និងផ្តល់វគ្គបណ្តុះបណ្តាលដល់ពួកគេ ។ ការលើកឡើងពីភ្នាក់ងារពេទ្យសុខភាពភូមិ គឺឆ្លុះបញ្ចាំង ពីភាពងាយរងគ្រោះរបស់កសិករទៅនឹងការប្រែប្រួលអាកាសធាតុ ទៅលើសុខភាពសត្វ ដូចមានគូសបញ្ជាក់នៅក្នុងសំណួរទី១ និង២ ។ ចំណុចចុងក្រោយគឺកសិករគិតថាពិន្ទុ VRA អាចលម្អបាន ប្រសិនបើមានការគាំទ្រផ្នែកស្ថាប័នពីសំណាក់រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។

តារាងខាងក្រោមបង្ហាញនូវការប្រៀបធៀបអំពីឧបសគ្គក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងវិធីដើម្បីកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ។ ការគិតឃើញបែបនេះ គឺដោយសារតែអង្គការមិនមែនរដ្ឋាភិបាលតែងតែផ្តល់ការគាំទ្រដល់ភូមិទាំងនេះ នៅពេលមានគ្រោះមហន្តរាយ ហេតុដូច្នេះបានជា ពួកគេត្រូវបានកសិករចាត់ទុកថាជាភ្នាក់ងារសំខាន់ក្នុងការកាត់បន្ថយភាពងាយរងគ្រោះនៅក្នុងភូមិ ។

| ឧបសគ្គ | ការកែលម្អពិន្ទុ |
|---|---|
| ១. កង្វះលទ្ធភាពក្នុងការប្រើប្រាស់ពូជស្រូវ កែលម្អខុសៗគ្នា ។ | ១. ស្តារប្រព័ន្ធធារាសាស្រ្ត ។ |
| ២. ខ្វះជំនាញនិងបច្ចេកទេសកសិកម្ម ។ | ២. ផ្តល់ពូជស្រូវកែលម្អខុសៗគ្នា ។ |
| ៣. ខ្វះធនធានទឹក ។ | ៣. ផ្តល់សេវាកសិកម្ម ។ |
| ៤. ខ្វះថវិកា ។ | ៤. សេវាកម្មសុខភាពសត្វ ។ |
| ៥. ខ្វះព័ត៌មានការប្រែប្រួលអាកាសធាតុ ។ | ៥. គាំទ្រផ្នែកស្ថាប័ន ។ |

ជាការគួរឱ្យភ្ញាក់ផ្អើល សេវាកម្មសុខភាពដែលជាវិធីមួយសម្រាប់កែលម្អពិន្ទុ VRA ត្រូវបានកត់សម្គាល់ ដោយអ្នកភូមិត្រឹមមួយចំនួនតូចប៉ុណ្ណោះ បើទោះជាកសិករមើលឃើញថា ការប្រែប្រួលអាកាសធាតុមាន ផលប៉ះពាល់អវិជ្ជមានខ្លាំងក្លាមកលើសុខភាព

មនុស្សក៏ដោយ (សូមមើលតារាងទី១ និងទី២ ខាងលើ) ។ កង្វះប្រាក់ ដែលបានកត់សម្គាល់ថាជាឧបសគ្គក្នុងការបន្សាំ មិនត្រូវបានលើកឡើងថាជាអាទិភាពខ្ពស់ឡើយនៅទីនេះ ដោយសារកសិករអាចចាប់ណាប់អារម្មណ៍លើសេវាកម្មនានា ដែលពួកគេអាចចំណាយប្រាក់ដើម្បីទិញជាងត្រឹមតែមានប្រាក់ ។

## ៥.៥ ការវិភាគទិន្នន័យដែលប្រមូលបាន

### ១. ផលិតភាពកសិកម្ម

#### ១.១ ផលប៉ះពាល់មកលើផលិតភាពកសិកម្ម

**១.១.១ ទឹកជំនន់ :** ភូមិនៅក្នុងខេត្តក្រចេះលិចទឹកជារៀងរាល់ឆ្នាំ ហើយកសិករមានទម្លាប់ចំពោះការជន់លិចប្រចាំឆ្នាំបែបនេះ ។ ដូច្នេះស្រូវត្រូវបានស្ទូងនៅមុនឬក្រោយទឹកជំនន់ (ស្រូវប្រដេញទឹក) ប៉ុន្តែជំនន់ខុសរដូវអាចបង្កមហន្តរាយលើស្រែរបស់ពួកគេ ។ទឹកជំនន់មានឥទ្ធិពលមកលើដំណាំស្រូវ នៅពេលដែលទឹកជំនន់មានកម្រិតខ្ពស់ពេក ស្រូវរលួយនៅក្រោមផ្ទៃទឹកឬទឹកជំនន់ខុសរដូវ ។

**១.១.២ គ្រោះរាំងស្ងួត :** គ្រោះរាំងស្ងួតទំនងជាប៉ះពាល់មកលើកសិករច្រើនជាង ។ វាធ្វើឱ្យសំណាបងាប់ប្រសិនបើកើតមាននៅក្នុងដើមរដូវធ្វើស្រែ ។ តាមធម្មតាកសិករអាចដាំស្រូវបាន ទោះជាយ៉ាងណាក៏ដោយការទទួលបានពូជថ្មីពីស្រូវដែលស្ទូងបាននោះត្រូវបានកត់សម្គាល់ថាជាឧបសគ្គចំពោះការបន្សាំ ។ គ្រោះរាំងស្ងួត និងកូនរដូវប្រាំងដែលកើតឡើងនៅពាក់កណ្តាលរដូវធ្វើស្រែនាំឱ្យស្រូវក្រិនដែលនាំឱ្យមានឥទ្ធិពលមកលើការដាក់គ្រាប់ដែលនាំឱ្យមានទិន្នផលទាប ។

**១.១.៣ កម្តៅ :** ដូចដែលនឹងពិភាក្សានៅក្នុងផ្នែកសុខភាពខាងក្រោម គ្រោះរាំងស្ងួត និងសីតុណ្ហភាពក្តៅខ្លាំងក៏មានឥទ្ធិពលមកលើសុខភាពសត្វនៅក្នុងភូមិនានាជាគោលដៅផងដែរ ។

#### ១.២ ដំណោះស្រាយរបស់កសិករ

**១.២.១ ពិពិធកម្មកសិកម្ម :** កសិករបានលើកឡើងថា ពួកគេត្រូវការការបង្កើនមុខដំណាំដែលកាត់បន្ថយហានិភ័យនៃការពឹងផ្អែកតែលើដំណាំស្រូវ ដូចជា ដាំបន្លែ សណ្តែក ពោត ដំឡូងមី និងដើមឈើហូបផ្លែជាដើម ។ ពួកគេក៏បានលើកឡើងផងដែរថាអំពីការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីគឺជាឧទាហរណ៍ផ្សេងទៀតអំពីការធ្វើពិពិធកម្មកសិកម្ម ។

**១.២.២ បច្ចេកទេសកសិកម្ម :** បន្ថែមលើការបង្កើនមុខដំណាំ កសិករក៏ចាប់អារម្មណ៍ផងដែរថាភាពងាយរងគ្រោះរបស់ពួកគេអាចកែលម្អបានប្រសិនបើពួកគេបានទទួលជំនាញប្រសើរជាងមុនអំពីការធ្វើស្រូវ និងដាំដំណាំផ្សេងទៀត និងចិញ្ចឹមសត្វ ក៏ដូចជាធ្វើវារីវប្បកម្មផងដែរ ។ ពួកគាត់ក៏បានសំណូមពរឱ្យមានការបណ្តុះបណ្តាលជំនាញធ្វើជីកំប៉ុស្តិ៍ និងវិធីសាស្ត្រគ្រប់គ្រងសត្វល្អិត ។ កសិករខ្លះ បានប្រាប់ឱ្យដឹងថាពួកគាត់ពុំដែល

បានទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសកសិកម្មឡើយ ។

**១.២.៣ ការកែលម្អពូជ** : កសិករក៏ចាប់អារម្មណ៍ផងដែរថាពូជស្រូវដែលបានកែលម្អ អាចកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគាត់ផងដែរ ។ នៅទីនេះ ការកែលម្អដែលបានលើកឡើង សម្តៅលើពូជដែលផ្តល់ទិន្នផលខ្ពស់ ឆាប់ផ្តល់ផល និងដែលធន់នឹងគ្រោះរាំងស្ងួត ។ កសិករបានលើកឡើងពីពូជមួយចំនួនដូចជា សែនពិដោ IR៦៦ ជាឧទាហរណ៍នៃពូជដែលបានកែលម្អ ។ ពូជស្រូវទាំងនេះ គឺជាពូជស្រូវក្រអូប ដែលមានតម្លៃថ្លៃនៅលើទីផ្សារ ។ ការទទួលបានពូជទាំងនេះគឺជាអាទិភាពខ្ពស់សម្រាប់កសិករ និងជាពិសេសមានលទ្ធភាពទទួលបានពូជបន្ថែមសម្រាប់ស្ទូងជាបន្តនៅពេលដែលសន្ទូងត្រូវបានបំផ្លាញ ។

## ១.៣ អន្តរាគមន៍របស់គម្រោង

**១.៣.១ ពិពិធកម្មកសិកម្ម** : គម្រោងអាចបង្ហាញ វារីវប្បកម្មតាមវិធីមួយដែលផ្តល់ប្រយោជន៍ដល់គ្រួសារច្រើនជាងដល់គ្រួសារមួយៗ ។ ទោះជាយ៉ាងណាក៏ដោយ គេត្រូវបង្កើតប្រភពដែលមានស្ថិរភាពនៃកូនត្រីពូជមុននឹងចូលប្រឡូកនៅក្នុងការធ្វើវារីវប្បកម្ម ។ គម្រោងក៏អាចលើកទឹកចិត្តឱ្យមានការដាំដំណាំនៅរដូវប្រាំង តាមរយៈការធ្វើពិសោធបង្ហាញ ការដាំបន្លែជាមួយក្រុមកសិករស្ត្រី ។ សកម្មភាពអាចធ្វើរួមផ្សំជាមួយការស្រោចស្រពដោយដំណក់ទឹក ដែលអនុញ្ញាតឱ្យកសិករមានប្រភពបន្ថែម សម្រាប់ប្រាក់ចំណូលនៅក្នុងរដូវប្រាំង ។ គម្រោងក៏អាចផ្សារភ្ជាប់ជាមួយការចិញ្ចឹមនិងគ្រប់គ្រងសត្វ ជាពិសេសរបៀបគ្រប់គ្រងជម្ងឺ លើសត្វគោ បសុសត្វ និងជ្រូកដោយសហការជាមួយកម្មវិធី RULIP ។

**១.៣.២ លទ្ធភាពទទួលបានពូជស្រូវកែលម្អ** : គម្រោងបានចាប់ផ្តើមរួចមកហើយនូវការពិសោធសាកល្បងលើពូជស្រូវដែលធន់នឹងគ្រោះរាំងស្ងួតនិងទឹកជំនន់ជាមួយនឹង CARDI ។ ទោះជាយ៉ាងណាក៏ដោយគម្រោងនេះអាចឈានមួយជំហានបន្ថែមទៀតដោយរួមបញ្ចូលនូវការសាកល្បងពូជ ដែលផ្តល់ទិន្នផលខ្ពស់និងមានតម្លៃថ្លៃដូចដែលកសិករបានលើកឡើងរួមមានពូជសែនពិដោ និង IR៦៦ ។ លើសពីនេះការបង្កើនពូជដែលកសិករចង់បានអាចធ្វើឱ្យកសិករមានលទ្ធភាពទទួលនូវពូជកាត់ល្អជាងមុន ក្នុងតម្លៃថោកជាងមុននិងបង្កើនភាពធន់ទ្រាំនៃពូជស្រូវរបស់កសិករទៅនឹងគ្រោះរាំងស្ងួត និងទឹកជំនន់ ។ ការបង្កើនពូជអាចរួមផ្សំជាមួយ ធនាគារគ្រាប់ពូជ ដែលអនុញ្ញាតឱ្យកសិករមានលទ្ធភាពទទួលបានពូជបន្ថែមនៅក្នុងករណីដែលសំណាបឬសន្ទូងរបស់ពួកបានខូចខាតដោយសារទឹកជំនន់និងគ្រោះរាំងស្ងួត និងបន្ទាប់មកតម្រូវការសាបពូជស្រូវឡើងវិញ ។

**១.៣.៣ ការផ្សព្វផ្សាយពីបច្ចេកទេសកសិកម្ម** : គម្រោងនឹងធានា ឱ្យមានការផ្សព្វផ្សាយពីបច្ចេកទេសកសិកម្មដល់កសិករដោយសារកសិករភាគច្រើននៅបុសលាវ បានបង្ហាញថាពួកគេមិនបានទទួលព័ត៌មានពីការផ្សព្វផ្សាយឡើយ ។ ឆ្លើយតបនឹងតម្រូវការកសិករគម្រោងនេះកំពុងអនុវត្តក្រោមភាពជាដៃគូជាមួយកម្មវិធីកែលម្អជីវភាពរស់នៅតាមជនបទ RULIP គាំទ្រដល់មន្ទីរកសិកម្មខេត្ត ក្នុងការផ្តល់សេវាកម្មផ្សព្វផ្សាយអំពីវិធីធ្វើស្រែ SRI ការដាក់ជី

នៅក្នុងជម្រៅដី និងការប្រើប្រាស់ជីសរីរាង្គដាក់ស្រែ និងដាំដំណាំជាដើម ។ ការផ្សព្វផ្សាយក៏រួមបញ្ចូលទាំងបច្ចេកទេសចិញ្ចឹមត្រី ការដាំដំណាំហូបផ្លែ និងការគ្រប់គ្រងសត្វផងដែរ ។ សកម្មភាពទាំងនេះអាចផ្សព្វផ្សាយតាមរយៈសាលារៀនស្រែកសិករដែលដឹកនាំបង្កើតដោយកម្មវិធី RULIP ។ ការសិក្សាដែលស្នើឡើងអំពីបទពិសោធកសិកម្មល្អៗ អាចនឹងជាពន្លឺសម្រាប់សកម្មភាពគម្រោងក្នុងការផ្សព្វផ្សាយអំពីបច្ចេកទេសដាំស្រូវ ។

## ២. ផលប៉ះពាល់មកលើសុខភាពមនុស្សនិងសត្វ

### ២.១ ឥទ្ធិពលការប្រែប្រួលអាកាសធាតុមកលើសុខភាព

**២.១.១ សុខភាពមនុស្ស** : នៅក្នុងឃុំបុសលាវ កសិករគិតថាការប្រែប្រួលអាកាសធាតុបង្កឱ្យមានរោគគ្រុនចាញ់ គ្រុនឈាម និងរាគរូស ។ កសិករបានបង្ហាញថាសុខភាពមនុស្សកាន់តែអាក្រក់ ដោយសារកង្វះគ្លីនិក ឬស្ថិតនៅឆ្ងាយ និងកង្វះថ្នាំពេទ្យ ។

**២.១.២ សុខភាពសត្វ** : កសិករក៏មានអារម្មណ៍ផងដែរថា ការប្រែប្រួលអាកាសធាតុ (គ្រោះរាំងស្ងួត[៣]) ក៏ធ្វើឱ្យសត្វឈឺផងដែរ ។ ជម្ងឺភាគច្រើនត្រូវបានរាប់បញ្ចូល អុតក្តាម និងសារទឹក ។

### ២.២ ដំណោះស្រាយរបស់កសិករ

**២.២.១ អនាម័យ** : ទោះបីសុខភាពមនុស្សកំពុងស្ថិតក្រោមការប៉ះពាល់ជាខ្លាំងពីការប្រែប្រួលអាកាសធាតុ ក៏ដោយមានតែភូមិមួយចំនួនតូចប៉ុណ្ណោះដែលបានស្នើសុំឱ្យមានមណ្ឌលសុខភាព ។ ជាជំនួស កសិករគូសបញ្ជាក់អំពីតម្រូវការឱ្យមានទឹកប្រកបដោយគុណភាពល្អ ដូចដែលបានពិភាក្សាខាងលើតាមរយៈការប្រើប្រាស់ធុងចម្រោះទឹក ។

**២.២.២ ការថែទាំសុខភាពសត្វ** : កសិករគិតថាការលើកកម្ពស់សុខភាពសត្វ អាចកាត់បន្ថយភាពងាយរងគ្រោះដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ។ ការថែទាំសុខភាពសត្វរួមមានការចាក់វ៉ាក់សាំង និងការបង្កើតឱ្យមានភ្នាក់ងារសុខភាពសត្វភូមិ រួមទាំងផ្តល់ការបណ្តុះបណ្តាលដល់ពួកគេផងដែរ ។

**២.២.៣ សត្វដែលធន់នឹងជម្ងឺ** : បន្ថែមពីលើការចាក់វ៉ាក់សាំង និង ការពង្រឹងភ្នាក់ងារសុខភាពសត្វភូមិ កសិករក៏យល់ឃើញថា ការមានលទ្ធភាពទទួលបាននូវពូជសត្វដែលធន់នឹងជម្ងឺ ក៏ជាកត្តាជួយកាត់បន្ថយភាពងាយរងគ្រោះផងដែរ ។

---

៣ គ្រោះរាំងស្ងួតធ្វើឱ្យសីតុណ្ហភាពឡើងខ្ពស់និងកម្តៅក្តៅខ្លាំង ដែលស្ថានភាពនេះកើតមានជាទូទៅនៅទូទាំងប្រទេសកម្ពុជា ។ កសិករបានសម្គាល់ឃើញថាជម្ងឺមានការកើននៅពេលសីតុណ្ហភាពឡើងខ្ពស់ ហើយសត្វទំនងជាងាប់ដោយសារកម្តៅក្តៅខ្លាំង ។

### ២.៣ អន្តរាគមន៍របស់គម្រោង

**២.៣.១ សុខភាពមនុស្ស** ៖ គម្រោងអាចពិនិត្យមើលលទ្ធភាពក្នុងការផ្តល់ធុងចម្រោះទឹក ។ ប៉ុន្តែជាជាងផ្តល់ធុងចម្រោះដោយឥតគិតថ្លៃគម្រោងនេះអាចផ្សារភ្ជាប់ការចែកចាយធុងចម្រោះជាមួយក្រុមសន្សំប្រាក់ ។ ដូច្នេះសាច់ប្រាក់ដែលបានពីការលក់ធុងចម្រោះ រួមចំណែកទៅក្នុងមូលនិធិសន្សំ ។ ដោយសារមាន NGOs កំពុងធ្វើការនៅក្នុងតំបន់ គម្រោងមានជម្រើសមួយផ្សេងទៀត ដោយចែកចាយតាមរយៈ NGOs ទាំងនោះដោយសារពួកគេ នៅបន្តសកម្មភាពជាមួយកសិករ នៅពេលដែលគម្រោងនេះត្រូវបានបញ្ចប់ ។

**២.៣.២ សុខភាពសត្វ** ៖ ទាក់ទងនឹងសុខភាពសត្វ គម្រោងនេះនឹងសហការជាមួយ RULIP លើរបៀបដើម្បីកែលម្អសេវាកម្មសុខភាពសត្វ ។ គម្រោង RULIP ចូលរួមនៅក្នុងកម្មវិធីចិញ្ចឹមជីវិតនៅជនបទ ដែលរួមមានការគ្រប់គ្រងសត្វចិញ្ចឹម (ការចិញ្ចឹមមាន់និងជ្រូក) សកម្មភាពទាំងនេះអាចពង្រីកសម្រាប់សត្វគោ ក៏ដូចជាពង្រឹងនូវភ្នាក់ងារសុខភាពសត្វភូមិផងដែរ ។

## ៣. ផលប៉ះពាល់មកលើការគ្រប់គ្រងធនធានទឹក

### ៣.១ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើធនធានទឹក

**៣.១.១ ទឹកសម្រាប់កសិកម្ម** ៖ កសិករបានកត់សម្គាល់ថា គ្រោះរាំងស្ងួតធ្វើឱ្យបឹងធម្មជាតិ ទំនប់ និងប្រព័ន្ធស្រោចស្រពរីងស្ងួត ដោយមានឥទ្ធិពលមកលើបរិមាណទឹកដែលមានសម្រាប់ការស្រោចស្រពស្រូវនិងដំណាំផ្សេងទៀតនៅក្នុងអំឡុងពេលនៃកូនរដូវប្រាំងនៅក្នុងរដូវវស្សា ។ ព្យុះនិងភ្លៀងធ្លាក់យ៉ាងច្រើន ក៏ធ្វើឱ្យខូចប្រព័ន្ធស្រោចស្រពផងដែរ ដែលមានន័យថាទឹកដែលតម្កល់ទុកសម្រាប់ការស្រោចស្រពត្រូវបាត់បង់ ។ ប៉ុន្តែបញ្ហាដ៏ធំជាងគេនៅក្នុងឃុំបុសលាវគឺកំណើនល្បាប់នៅក្នុងប្រព័ន្ធស្រោចស្រព ដោយសារតែសំណឹកពីទីជុំវិញ ដែលធ្វើឱ្យទំនប់កាន់តែរាក់បន្តិចម្តងៗ ដូច្នេះវាអាចតម្កល់ទឹកទុកបានក្នុងកម្រិតកំណត់តែប៉ុណ្ណោះ ។

**៣.១.២ ទឹកសម្រាប់ប្រើប្រាស់តាមផ្ទះ** ៖ មិនដូចនៅឃុំទឹកក្រហមឡើយដែលរាំងស្ងួតជាងនិងមិនសូវមានស្ទឹង មានតែភូមិមួយចំនួនតូចប៉ុណ្ណោះដែលបានពោលថាការរីងស្ងួតនៃអណ្តូងនានាគឺជាឧបសគ្គក្នុងការទទួលបានទឹកសម្រាប់ប្រើប្រាស់តាមផ្ទះ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកភូមិភាគច្រើនបានកត់សម្គាល់ថា ការថយចុះនៃគុណភាពទឹកនៅក្នុងពេលមានគ្រោះរាំងស្ងួតនិងនៅក្នុងរដូវប្រាំងគឺជាបញ្ហាចម្បង ។ ជាលទ្ធផល ពួកគេបានកត់សម្គាល់ថាធុងចម្រោះអាចជាជម្រើសចំពោះបញ្ហានេះ ។

## ៣.២ ដំណោះស្រាយរបស់កសិករ

**៣.២.១ ទឹកសម្រាប់ស្រោចស្រព:** ភាពចាំបាច់ដើម្បីធ្វើឱ្យល្អឡើងវិញ និងជីកស្តារ បឹង ទំនប់ និងប្រឡាយសម្រាប់ការស្រោចស្រព ដើម្បីផ្តល់ទឹកសម្រាប់សត្វ និងសម្រាប់ដាំបន្លែនៅក្នុងរដូវប្រាំង ត្រូវបានកសិករទាំងអស់កត់សម្គាល់ ។ កសិករចំនួន ៤ភូមិ បានលើកឡើងពីតម្រូវការនូវម៉ាស៊ីនបូមទឹក ជាវិធីសាស្ត្រក្នុងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ទៅលើធនធានទឹកសម្រាប់វិស័យកសិកម្ម ។

**៣.២.២ ទឹកសម្រាប់ប្រើប្រាស់តាមគ្រួសារ** : កសិករក៏បានគូសបញ្ជាក់ផងដែរអំពីការថយចុះគុណភាពទឹកនៅក្នុងរដូវប្រាំងនិងតម្រូវការទឹកស្អាត ។

## ៣.៣ អន្តរាគមន៍របស់គម្រោង

**៣.៣.១ កែលម្អប្រព័ន្ធធារាសាស្ត្រ** : សកម្មភាពនានានៅក្រោមការគ្រប់គ្រងធនធានទឹក នឹងត្រូវធ្វើឡើងរួមជាមួយវិស័យកសិកម្ម ។ និយាយម៉្យាងទៀត ការស្តារទំនប់ស្រោចស្រពអាចនឹងនាំឱ្យមានកំណើនផលិតកម្មដំណាំឬមួយតាមរយៈការស្រោចស្រពពេលមានកួនរដូវប្រាំង ឬការស្រោចស្រពបន្លែ និងដំណាំផ្សេងទៀតនៅក្នុងរដូវប្រាំង ។ គួរកត់សម្គាល់ថាមិនដូចខេត្តព្រះវិហារទេ ការស្តារទំនប់ស្រោចស្រព មានការផ្សារភ្ជាប់ជាមួយការជីកស្តារប្រព័ន្ធនានាដែលកាន់តែរាក់ ដោយសារតែកំណកល្បាប់ ហើយរាល់ការងារលើប្រព័ន្ធស្រោចស្រពនានា គួរតែធ្វើឡើងដោយការអភិរក្សទំនប់និងតំបន់ជុំវិញនោះ ។ ទោះបីគម្រោងនេះមិនមែនជាគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនិងមិនអាចកសាងទំនប់និងផ្លូវថ្នល់ក៏ដោយគម្រោងនេះនឹងអនុវត្តបង្ហាញពីរបៀបកសាងប្រព័ន្ធស្រោចស្រពដែលធន់ទ្រាំនឹងអាកាសធាតុ ដែលអាចទប់ទល់នឹងផលប៉ះពាល់ពីកំណើនគ្រោះថ្នាក់នៃអាកាសធាតុ ដូចជាខ្យល់ព្យុះ និងទឹកជំនន់ ។ ក្នុងន័យនេះប្រព័ន្ធស្រោចស្រពព្រែកតាទឹង ត្រូវបានធ្វើអត្តសញ្ញាណនៅឃុំបុសលាវ សម្រាប់ការអនុវត្តបង្ហាញអំពីភាពធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ ។ ឆ្លើយតបទៅនឹងតម្រូវការម៉ាស៊ីនបូមទឹករបស់កសិករនៅរដូវប្រាំង គម្រោងនឹងពិនិត្យមើលបច្ចេកវិទ្យាសមស្រប ដែលអាចផ្តល់សេវាកម្មដូចគ្នាជាមួយតម្លៃសមស្រប ។ គម្រោងនេះនឹងអនុវត្តសាកល្បងអំពី ការបូមទឹកដោយប្រើប្រាស់ថាមពលខ្យល់ និងថាមពលព្រះអាទិត្យផងដែរ ប្រសិនបើអាចធ្វើបាន ។

**៣.៣.២ ទឹកសម្រាប់ប្រើប្រាស់តាមគ្រួសារ** : ជាបឋមគម្រោងគួរកត់សម្គាល់អំពី NGOs ដែលកំពុងផ្តល់សេវាទាំងនេះ និងនៅក្នុងភូមិនីមួយៗ ។ ក្នុងករណីដែលមានភាពខុសគ្នា គម្រោងនេះអាចចូលរួមនៅក្នុងការផ្តល់ធុងចម្រោះទឹក ឬសហការជាមួយ NGOs សមស្របដើម្បីផ្តល់សេវានេះ ។

# ៦. បទពិសោធន៍ចម្បងៗដែលទទួលបាន



*ការសិក្សាវាយតម្លៃនេះបានចងក្រងនូវស្ថានភាពងាយរងគ្រោះរបស់កសិករទៅនឹងឥទ្ធិពលការប្រែប្រួលអាកាសធាតុ សម្រាប់គម្រោងធ្វើសកម្មភាពឆ្លើយតប ។*

- ☐ នៅក្នុងស្ថានភាពសមស្រប VRA គួរតែធ្វើឡើងមុននឹងបង្កើតឯកសារគម្រោង ដើម្បីឆ្លុះបញ្ចាំងអំពីទស្សនៈនិងតម្រូវ-ការរបស់សហគមន៍គោលដៅ ។ នៅក្នុងករណីនេះ VRA ត្រូវបានធ្វើឡើងនៅក្រោយមានឯកសារគម្រោងរួចហើយ ។ ទោះជាយ៉ាងណាក៏ដោយ របកគំហើញបង្ហាញថាគម្រោងនេះនៅតែអាចឆ្លើយតបនៅក្នុងវិសាលភាពនៃក្របខ័ណ្ឌគម្រោង ដោយគ្រាន់តែកែតម្រូវផែនការការងារសម្រាប់សកម្មភាពគម្រោង ដើម្បីបំពេញតម្រូវការរបស់កសិករ ។

- ☐ តាមតែអាចធ្វើបាន VRA គួរតែកែតម្រូវទៅតាមកាលវិភាគនៅមូលដ្ឋាន ។ គម្រោងនេះបានអនុវត្ត VRA នៅក្នុងរដូវដាំដំណាំ ដែលមានន័យថាអ្នកដែលសកម្មបំផុតនៅក្នុងទិដ្ឋភាពសេដ្ឋកិច្ច មិនអាចចូលរួមបានឡើយ ។ ជាលទ្ធផលទស្សនៈរបស់ពួកគាត់អាចមិនត្រូវបានយកមកពិចារណាឡើយ ។

- ☐ ប្រការសំខាន់គឺត្រូវចំណាយពេលជាមួយអ្នកសម្របសម្រួល VRA ដើម្បីពិនិត្យមើលសំណួរ VRA ជាភាសារបស់អ្នក នៅមូលដ្ឋាន ដើម្បីធានាថាមានការយល់ដឹង ក្នុងកម្រិតដូចគ្នាលើសំណួរនិងពាក្យ ដែលប្រើប្រាស់នៅក្នុង VRA ។ ពាក្យនានាដូចជា "បន្សាំ" និង "ព្យាករណ៍" ដែលអ្នកសម្របសម្រួលមិនងាយនឹងយល់ច្រឡំ តែអ្នកភូមិអាចច្រឡំ ។

- ☐ សំណួរទី ៤ គួរតែសួរនៅក្នុងការវាយតម្លៃពាក់កណ្តាលគម្រោង ដើម្បីវាស់ស្ទង់អំពីការរីកចម្រើនធៀបនឹងការកាត់បន្ថយភាពងាយរងគ្រោះ ។ ដោយសួរអ្នកភូមិថាតើពួកគេមានទំនុកចិត្តកម្រិតណាលើគម្រោងមួយ ដែលពួកគេនៅពុំទាន់បានឃើញឬបានចូលរួមនៅក្នុងសកម្មភាពនៃគម្រោងនោះបានពេញលេញ ពិតជាមិនផ្តល់ផលឡើយ ។

គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រង
ធនធានទឹកនិងការប្រកបរបរកសិកម្ម (NAPA Follow-Up project)
ទូរស័ព្ទ: ០២៣ ២២១ ១២០
អ៊ីម៉ែល: kimthourn@gmail.com